**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**



# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ

# (ផយអជ)

# ២០១៤-២០១៨

# RURAL STRATEGIC DEVELOPMENT PLAN

# (RSDP)

## 2014- 2018

រៀបចំដោយ នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ

ក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ/ អនុក្រុមទី១ រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រថវិកា ត្រួតពិនិត្យ វាយតម្លៃ និងរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ

**MRD - PFMRP/Sub Group1**

ខែ មាឃ ឆ្នាំ ម្សាញ់ ព.ស. ២៥៥៧ ត្រូវនឹង ខែ កុម្ភៈ គ.ស ២០១៤

# អារម្ភកថា

ក្នុងគោលបំណងបន្តបេសកកម្មបម្រើជាតិ មាតុភូមិ និងប្រជាជន ព្រមទាំងប្រែក្លាយតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានការអភិវឌ្ឍ មានវិបុលភាព ជាមួយនឹងក្តីសង្ឃឹមរបស់ប្រជាជនដែលរស់នៅក្នុងភាពសុខដុមរមនា មានជីវភាពកាន់តែប្រសើរឡើង ក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយមានការចូលរួមចំណែកគាំទ្រពីអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងប្រជាជនគ្រប់ទីកន្លែង រួមជាមួយនឹងការជួយជ្រោមជ្រែងពីម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា បានបន្តខិតខំយ៉ាងសកម្មធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការបន្តកសាងផ្លូវជនបទ ការរៀបចំឱ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រងនិងថែទាំផ្លូវជនបទ ដោយមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសការកែលម្អផ្លូវជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬ ផ្លូវបេតុង។ នេះជាគោលដៅយុទ្ធសាស្ត្រដ៏សំខាន់ ដែលនឹងចូលរួមដល់ការជំរុញកំណើនសេដ្ឋកិច្ច ការលើកកម្ពស់ជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជនបទ ។

ក្រសួងអភិវឌ្ឍន៍ជនបទ នឹងបន្តសម្រេចគោលដៅឆ្នាំ ២០១៨ ដើម្បីឱ្យប្រជាជននៅជនបទចំនួន ៦០% បានទទួលសេវាផ្គត់ផ្គង់ទឹកស្អាត ហើយនៅឆ្នាំ ២០២៥ ប្រជាជនគ្រប់រូបដែលរស់នៅក្នុងសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយចីរភាព ។

ក្រសួងក៏បន្តអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីកែលម្អ លើកកម្ពស់ជីវភាពប្រជាជននៅជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុកស្វែងរកការងារ តាមរយៈការជំរុញវិស័យឥណទានជនបទ ដើម្បីផ្តល់សេវាប្រាក់កម្ចី ដែលមានអត្រាការប្រាក់សមរម្យជូនប្រជាជននៅជនបទ ការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការជំរុញការអភិវឌ្ឍសិប្បកម្ម សហគ្រាស និងមុខជំនាញខ្នាតគ្រួសារ ខ្នាតតូច និងមធ្យម ដោយយកចិត្តទុកដាក់ផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ ព្រមទាំងការខិតខំពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ ។

ក្រសួងបន្តអភិវឌ្ឍតំបន់ជនជាតិដើមភាគតិចរស់នៅ ឱ្យមានការរីកចម្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិពេញលេញរបស់បងប្អូនជនជាតិដើមភាគតិច ក្នុងការចូលរួមធ្វើសេចក្តីសម្រេចនានា ដើម្បីកសាងគោលនយោបាយជាតិ ធានាសិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់សម្រាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ ប្រពៃណី និងភាសារបស់បងប្អូនជនជាតិ ។

កិច្ចការទាំងឡាយខាងលើ នឹងចូលរួមចំណែកជំរុញឱ្យប្រទេសកម្ពុជាចេញផុតពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលដ៏ឆាប់ខាងមុខ ។

ថ្ងៃអង្គារ ៤កើត ខែផល្គុន ឆ្នាំម្សាញ់ ព.ស. ២៥៥៧

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា គ.ស. ២០១៤

**រដ្ឋមន្ត្រី**

**ជា សុផារ៉ា**

ក្រសួងអភិវឌ្ឍន៍ជនបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៤ -២០១៨
# (ផយអជ ២០១៤ - ២០១៨ )

## មាតិកា

ទំព័រ


**ផ្នែកទី១**

**លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ -២០១៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ**

១- សេចក្តីផ្តើម........................................................ ២

២- របាយការណ៍ស្តីពីការអនុវត្តផែនការឆ្នាំ ២០០៩ -២០១៣........................ ៣

៣- តារាងវាយតម្លៃសូចនាករដែលបានអនុវត្តក្នុង ផយអជ ២០០៩ -២០១៣.................. ១១

៤- បញ្ហាប្រឈមលើវិស័យអភិវឌ្ឍន៍ជនបទ........................................ ១៣

៥- វិធានការដោះស្រាយ...................................................... ១៣

៦- សេចក្តីសន្និដ្ឋាន........................................................ ១៤

**ផ្នែកទី២**

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ (ផយអជ) ឆ្នាំ ២០១៤ -២០១៨**

១- សេចក្តីផ្តើម........................................................ ១៨

២- ចក្ខុវិស័យ........................................................................................................................ ២០
៣- គោលបំណង និងគោលដៅ.................................................................................................... ២០
៤- គោលនយោបាយអភិវឌ្ឍន៍ជនបទ............................................................................................ ២០
៥- ទិសដៅនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ........................................................................ ២២
៦- បេសកកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ................................................................................ ២២
៧- យុទ្ធសាស្ត្រអាទិភាព.............................................................................................................. ២៣
៨- ផែនការសកម្មភាពអនុវត្ត ផយអជ ២០១៤-២០១៨....................................................................... ២៣
៩- តម្រូវការធនធានសម្រាប់អនុវត្ត ផយអជ ២០១៤-២០១៨............................................................. ២៦
១០- តម្រូវការធនធានសម្រាប់អនុវត្តផែនការវិនិយោគសាធារណៈ ឆ្នាំ ២០១៤-២០១៨.................... ២៩
១១- តារាងតាមដាន និងវាយតម្លៃការអនុវត្ត ផយអជ ២០១៤-២០១៨............................................... ៣០
១២- តារាងតាមដានសូចនាករការអនុវត្ត ផយអជ ឆ្នាំ ២០១៤-២០១៨............................................... ៣១
១៣- សេក្តីសន្និដ្ឋាន..................................................................................................................... ៣២

# ផ្នែកទី១

# លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ





## ១-សេចក្តីផ្តើម

ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៩៣ ក្នុងគោលដៅចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមជនបទ ។ ការអភិវឌ្ឍជនបទតាមរូបភាពចម្រុះរួមមានផ្នែកទន់ ( Software ) និងផ្នែករឹង ( Hardware ) ។ ការអភិវឌ្ឍផ្នែកទន់ សំដៅដល់ការចូលរួមការពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលទាំងផ្នែកមន្ត្រីថ្នាក់កណ្តាល និងថ្នាក់សហគមន៍ជនបទដើម្បីបង្កើនចំណេះដឹងជំនាញវិជ្ជាជីវៈ ក្រមសីលធម៌មន្ត្រីរាជការ និងការអប់រំប្រជាពលរដ្ឋអំពីទឹកស្អាត អនាម័យដើម្បីធានាប្រសិទ្ធភាពការងារ ភាពជាម្ចាស់ និងបង្កើនប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋតាមតំបន់ជនបទផងដែរ ។ ចំពោះការអភិវឌ្ឍផ្នែករឹងសំដៅដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា÷ ផ្លូវជនបទ សំណង់សិល្បការ ការសាងសង់បង្គន់អនាម័យ ការសាងសង់អណ្តូងទឹក ស្រះទឹក ទំនប់ទឹក ប្រព័ន្ធធារាសាស្ត្រខ្នាតតូច សាលារៀន មណ្ឌលសុខភាព ។ល។ ជាលទ្ធផល ក្រសួងអភិវឌ្ឍន៍ជនបទបានចូលរួមចំណែកធ្វើឲ្យតំបន់ជនបទមានការប្រែប្រួលយ៉ាងច្រើនក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនេះដែលបានជួយជំរុញកំណើនសេដ្ឋកិច្ចជាតិដល់ជាង ៧ % ក្នុងឆ្នាំ ២០១១ ហើយភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨០%[1] ក្នុងឆ្នាំ ២០០៧ មកត្រឹមជាង ១៩,៨០ % ក្នុងឆ្នាំ ២០១១ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗបានកើនឡើងរហូតដល់ជាង ១,០០០ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៣ ។

ជាទិដ្ឋភាពរួម តំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជាមានការវិវត្តជាវិជ្ជមាន រហូតដល់ពេលនេះតំបន់ជនបទមួយភាគធំដែលនៅជិតទីប្រជុំជនមានចរន្តអគ្គិសនីប្រើប្រាស់រួចហើយ ផ្លូវជនបទមួយចំនួនត្រូវបានចាប់ផ្តើមផ្លាស់ប្តូរកម្រាលពីក្រួសក្រហមទៅជាកៅស៊ូពីរជាន់ (DBST) ការផ្គត់ផ្គង់ទឹកស្អាតគ្របដណ្តប់បាន ៤២,០០ % និងអនាម័យបានជាង ៣៣ % នៃតំបន់ជនបទទូទាំងប្រទេស ។ ប្រជាពលរដ្ឋជនបទមួយចំនួនធំកំពុងទទួលផលចំណេញពីផលិតកម្ម កសិកម្ម សេវាកម្ម ឧស្សាហកម្មធុនស្រាល និងមធ្យមបានចាប់ផ្តើមផ្លាស់ប្តូរលំនៅដ្ឋានពីផ្ទះតូចប្រក់ស្លឹកមកជាផ្ទះធំខ្ពស់ប្រក់ក្បឿង ខ្លះប្រក់ស័ង្កសី និងមួយចំនួនតូចបានធ្វើជញ្ជាំងឥដ្ឋដំបូលប្រក់ក្បឿងរួចហើយ ។ ចំនួនម៉ូតូ ទូរទស្សន៍ ទូរស័ព្ទដៃតាមគេហដ្ឋាននីមួយៗក៏មានការកើនឡើងដែរ ។ ក្រៅពីនេះ នៅតាមវាលស្រែធំៗនៃតំបន់មួយចំនួនតាមទំនាបបឹងទន្លេសាបដូចជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តមួយចំនួនទៀតនៃតំបន់ដីសណ្តរទន្លេមេគង្គ កសិករបានប្រើប្រាស់គ្រឿងយន្តកសិកម្មដូចជា ត្រាក់ទ័រភ្ជួររាស់ដី ម៉ាស៊ីនច្រូតកាត់ស្រូវ និងម៉ាស៊ីនបោកបែនស្រូវ ។ ទាំង

[1] របាយការណ៍ក្រសួងផែនការ ឆ្នាំ ២០១៣

អស់នេះបានឆ្លុះបញ្ចាំងពីការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទដែលបានទទួលផលពីគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៤ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

## ២-របាយការណ៍ស្តីពីការអនុវត្តផែនការឆ្នាំ ២០០៩-២០១៣

រយៈពេល ៥ ឆ្នាំ ២០០៩ ដល់ ២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើនដូចខាងក្រោម÷

### ២.១ ការងាររៀបចំផែនការយុទ្ធសាស្ត្រ និងថវិកា

ស្ថិតក្នុងបរិការណ៍នៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទ បានអនុវត្តកម្មវិធីនេះប្រកបដោយជោគជ័យតាមរយៈការធ្វើសមាហរណកម្មរវាងផែនការ និងថវិកាដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរបស់ក្រសួង ។ ក្នុងនោះក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ( BSP ) រយៈពេលបីឆ្នាំបន្តបន្ទាប់ ផែនការវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល និងផែនការថវិកា (PB) ប្រចាំឆ្នាំដែលមានគោលបំណង គោលដៅសកម្មភាព លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយច្បាស់លាស់តាមឆ្នាំនីមួយៗជារៀងរាល់ឆ្នាំ ។ រយៈពេល ៥ ឆ្នាំ ពីឆ្នាំ ២០០៩ ដល់ ២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទបានបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន ២២២៥ នាក់ក្នុងនោះរួមមាន÷ វគ្គបណ្តុះបណ្តាលផែនការថវិកាចំនួន ១៥ វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១ ៥៧៥ នាក់ក្នុងនោះមន្ត្រីថ្នាក់កណ្តាលដែលជាអ្នកអនុវត្តផ្ទាល់ចំនួន ៤៩៥ នាក់ និងថ្នាក់រាជធានី ខេត្ត ១ ០៨០ នាក់ដែលក្នុងនោះភាគច្រើនជាប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីរទទួលបន្ទុកផែនការ ប្រធានការិយាល័យ អនុប្រធានការិយាល័យផែនការ - ស្ថិតិ និងប្រធាន អនុប្រធានការិយាល័យគណនេយ្យ ។ ផែនការថវិកាតាមកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើការសាកល្បងចាប់តាំងពីឆ្នាំ២០០៧ មករហូតដល់ពេលនេះមានរយៈពេល ៧ ឆ្នាំ ហើយ ។ ផែនការថវិកាតាមកម្មវិធីបែងចែកជា ៣ កម្មវិធី ១១ អនុកម្មវិធី និង ៤០ សកម្មភាពសម្រាប់អនុវត្តកម្មវិធីនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។ ក្រៅពីនេះក្រសួងបានបើកវគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃផែនការ និងការកសាងគម្រោងចំនួន ៥ វគ្គតាមបណ្តាខេត្តសម្រាប់មន្ត្រីការិយាល័យថ្នាក់ស្រុកចំនួន ២០០ នាក់ ។ បណ្តុះបណ្តាលជំនាញកំព្យូទ័រថ្នាក់កម្រិតមូលដ្ឋាន និង

កម្រិតខ្ពស់ដល់មន្ត្រីក្រសួងចំនួន ១៥ វគ្គមានសិក្ខាកាមចំនួន ៤៥០ នាក់ ។ ក្រសួងបានរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃថវិកាកម្មវិធីរួចហើយៗនឹងត្រូវដាក់ឲ្យដំណើរការក្នុងឆ្នាំ ២០១៤ ។

## ២.២ -ការបណ្តុះបណ្តាល និងការគ្រប់គ្រងហិរញ្ញវត្ថុ

ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំសិក្ខាសាលា ស្តីពីនីតិវិធីនៃការទូទាត់ នីតិវិធីលទ្ធកម្ម នីតិវិធីនៃការចំណាយថវិកាតាមកម្មវិធី បែបបទនៃការគ្រប់គ្រងសារពើពន្ធដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៦៧៨ នាក់ មកពីនាយកដ្ឋានចំនួន ១១ អគ្គាធិការ ដ្ឋាន ក្រុមការងារយេនឌ័រ និងមន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៤ រាជធានី-ខេត្តដែលមានចំនួន ៨ វគ្គ មានប្រធានបទដូចខាងក្រោម÷

- សិក្ខាសាលាស្តីពី ការទូទាត់រជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីនៅខេត្តព្រះសីហនុចំនួន ២ វគ្គ
- សិក្ខាសាលាស្តីពី ការពង្រឹងសមត្ថភាពលើការរៀបចំថវិកាកម្មវិធីនៅខេត្តបាត់ដំបងចំនួន ២ វគ្គ
- សិក្ខាសាលាស្តីពី ការពង្រឹងសមត្ថភាពលើការទូទាត់ថវិកាកម្មវិធីនៅខេត្តកំពង់ចាម ២ វគ្គ
- សិក្ខាសាលាស្តីពី ការពង្រឹងសមត្ថភាពលើការអនុវត្តថវិកាកម្មវិធីនៅខេត្តសៀមរាប ២ វគ្គ

គោលបំណងនៃសិក្ខាសាលាខាងលើ គឺដើម្បីពង្រឹងសមត្ថភាពការរៀបចំអនុវត្តថវិកាតាមកម្មវិធីឲ្យបានត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ ។ លទ្ធផលនៃសិក្ខាសាលាខាងលើបានធ្វើឲ្យមន្ត្រីបង្គោលផ្នែកគណនេយ្យ ហិរញ្ញវត្ថុ និងសារពើភ័ណ្ឌអាចរៀបចំឯកសារទូទាត់ត្រឹមត្រូវ និងទាន់ពេល ។

## ២.៣ ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្ស

ការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍមានសារៈសំខាន់ខ្លាំងណាស់ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។ គោលដៅចម្បងនៃការអភិវឌ្ឍធនធានមនុស្ស គឺសំដៅជំរុញការអភិវឌ្ឍស្ថាប័ន និងពង្រឹងសមត្ថភាពមន្ត្រីស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឲ្យមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទមានសមត្ថភាពគ្រប់គ្រាន់ប្រកបដោយគុណភាព ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

ការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានមនុស្សមានពីរផ្នែកគឺ ការបណ្តុះបណ្តាលមន្ត្រីរាជការថ្នាក់កណ្តាល និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានថ្នាក់សហគមន៍ដល់ប្រជាពលរដ្ឋក្រីក្រតាមរយៈ ÷

- ការសិក្សាវាយតម្លៃតម្រូវការបណ្តុះបណ្តាលមន្ត្រីនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត

- ការផ្សព្វផ្សាយគោលនយោបាយស្តីពី ការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ការពង្រឹងសមត្ថភាពមន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ
- ការរៀបចំព្រឹត្តិប័ត្រព័ត៌មានរបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ផ្សព្វផ្សាយ

ក្រសួងមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានចំនួន ៥ កំពុងអនុវត្តស្ថិតនៅខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តកំពង់ចាម ។ ក្នុងឆ្នាំ ២០១៣ កន្លងនៅនេះ ក្រសួងបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមូលដ្ឋានពីរបន្ថែមទៀតនៅខេត្តពោធិសាត់ និងខេត្តបាត់ដំបង ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមូលដ្ឋាន បានធ្វើការបណ្តុះបណ្តាលលើជំនាញមួយចំនួនដូចជា កាត់សក់ អ៊ុតសក់ កែសម្ផស្ស សិប្បកម្ម ជួសជុលម៉ាស៊ីនភ្លើង ម៉ាស៊ីនកសិកម្មខ្នាតតូច ជួសជុលម៉ូតូ ជួសជុលរថយន្ត ជួសជុលគ្រឿងអេឡិចត្រូនិច និងបណ្តុះបណ្តាលភាសាអង់គ្លេស ជូនដល់ប្រជាពលរដ្ឋក្រីក្រនៅតាមខេត្តគោលដៅខាងលើ ។ ជាលទ្ធផលនៃការអនុវត្តផែនការ ៥ ឆ្នាំ ២០០៩ - ២០១៣ មានដូចខាងក្រោម÷

- *ការបណ្តុះបណ្តាលមន្ត្រីរាជការរបស់ក្រសួង ១៤ ២១៣ នាក់ (ស្រី ២ ២១០ នាក់ )*
- *ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋ ៥ ៤៧២ នាក់ ( ស្រី ១ ៩៧៤នាក់ )*

## ២.៤ ការងារសេដ្ឋកិច្ចជនបទ

ក្រសួងអភិវឌ្ឍន៍ជនបទ កំពុងជួយជំរុញសេដ្ឋកិច្ចនៅតាមសហគមន៍ជនបទ ឲ្យមានការរីលូតលាស់តាមរយៈការជួយសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសឈានដល់ការផ្តល់ឥណទានជូនប្រជាពលរដ្ឋនៅជនបទសម្រាប់បង្កើត និងពង្រីកមុខរបរ ឬអាជីវកម្មខ្នាតតូចព្រមទាំងជួយសម្របសម្រួលបង្កើតជាបណ្តាញផ្សារភ្ជាប់ទំនាក់ទំនងរវាងផលិតករ និងទីផ្សារដោះដូរផលិតផលនៅទីជនបទ ។ ផ្តល់ឥណទានជនបទដល់សហគ្រាសខ្នាតតូច សិប្បកម្មខ្នាតតូច សម្រួលទីផ្សារផលិតផលកសិកម្ម និងផ្តល់បច្ចេកទេសជំនាញផ្សេងៗទៀតដើម្បីបង្កើតមុខរបរបង្កើនប្រាក់ចំណូលគ្រួសារសំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅជនបទ ។

ក្នុងរយៈពេល ៥ ឆ្នាំ ២០០៩ -២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានលទ្ធផលដូចខាងក្រោម÷

- បើកសិក្ខាសាលាផ្សព្វផ្សាយ និងផ្តួចផ្តើមគំនិតលើការបើកមុខរបរអាជីវកម្មថ្មីស្តីពី÷
  - *អត្ថប្រយោជន៍នៃឡជីវឧស្ម័ន និងចង្ក្រាននាងកង្រី មានអ្នកចូលរួមចំនួន ៣៦៧ នាក់*
  - *គំនិតផ្តួចផ្តើមបង្កើតមុខរបរ និងគ្រប់គ្រងអាជីវកម្មបាន ៤៦៤ នាក់*

- *ព័ត៌មានទីផ្សារផលិតផលកសិកម្ម និងរបៀបគ្រប់គ្រងឥណទាន បាន ១៧១ នាក់*

❖ ការអនុវត្តផ្ទាល់តាមគ្រួសារក្រីក្រ ៖

- *ផ្ទេរបច្ចេកទេសផលិតឡជីវឧស្ម័នបាន ៣៥ គ្រួសារ*
- *ផ្ទេរបច្ចេកទេសផលិតចង្ក្រាននាងកង្រីបាន ៦០ គ្រួសារ*
- *ផ្ទេរបច្ចេកទេសត្បាញក្រមា បាន ៤៥ គ្រួសារ*
- *ផ្ទេរបច្ចេកទេសត្បាញហូលបាន ៧៥ គ្រួសារ*
- *សហប្រតិបត្តិការជាមួយអង្គការ NGOs សហគ្រាសមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់ឥណទានជនបទ ។*

## ២.៥ ការអភិវឌ្ឍសហគមន៍

ការអភិវឌ្ឍសហគមន៍ ជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ និងបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋាន ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការផ្តល់ជំនាញមូលដ្ឋានដល់សហគមន៍ជនបទសម្រាប់បង្កើតមុខរបរ និងការបង្កើនសមត្ថភាពសហគមន៍ទប់ស្កាត់ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយផ្សេងៗនៅតាមសហគមន៍ ។នេះជាយន្តការគន្លឹះមួយដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន សំដៅធ្វើឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយាឥរិយាបថ និងផ្នត់គំនិតរបស់សហគមន៍ជនបទ ដើម្បីធានាការអភិវឌ្ឍមានភាពជាម្ចាស់ ។ តួនាទីសំខាន់របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ គឺការបង្កើត និងពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ.) អភិវឌ្ឍន៍ភូមិចម្រុះ លើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ កាត់បន្ថយអនក្ខរភាព និងការអភិវឌ្ឍមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ ។

រយៈពេល ៥ ឆ្នាំ ២០០៩-២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានលទ្ធផលដូចខាងក្រោម ៖

- *រៀបចំបោះឆ្នោតឡើងវិញដល់ គ.អ.ភ.ដែលផុតអាណត្តិបានចំនួន ២៤៦ ភូមិ*
- *បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់មន្ទីរបានចំនួន ៣០ វគ្គ ដែលមានសិក្ខាកាមចំនួន ៤១០ នាក់*
- *បណ្តុះបណ្តាលគ្រួសារសហគមន៍ និង គ.អ.ភ បានចំនួន ៤៣ វគ្គ មានអ្នកចូលរួម ១.០៨០ នាក់*
- *បណ្តុះបណ្តាលគ្រូបង្គោលស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅតាមសហគមន៍ បានចំនួន ២ វគ្គ ដែលមានសិក្ខាកាមចំនួន ៧០ នាក់*

- បណ្តុះបណ្តាល គ.អ.ភ. ស្តីពី តួនាទីភារកិច្ចរបស់ គ.អ.ភ. និងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ ទាំង ២៤ រាជធានី ខេត្ត ចំនួន ៤២៣ វគ្គ មានសិក្ខាកាមចំនួន ១៣ ៣៩៨ នាក់
- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់មន្ទីរបានចំនួន ១៨ វគ្គ ដែលមានសិក្ខាកាមចំនួន ២០០ នាក់
- បង្រៀនអក្ខរកម្មបានចំនួន ១០១ ថ្នាក់ ដែលមានសិក្ខាកាមចំនួន ១.៩៨៧ នាក់ស្រី ១.៣៨២ នាក់
- ផ្សព្វផ្សាយសារាចរណែនាំស្តីពី ការអនុវត្តប្រកាសអន្តរក្រសួងលេខ ២៣៩១ ប្រក ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ ទាំង ២៤ រាជធានី ខេត្ត ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤ ៣៤៧ នាក់ ស្រី ចំនួន ៥៥៨ នាក់
- ផ្តល់ស្រូវពូជជូនសហគមន៍បាន ៦២៥ តក្រ
- ស្តារប្រឡាយតូចៗបាន ០២ ខ្សែប្រវែង ២ ៤០០ ម៉ែត្រ
- សាងសង់ទ្វារទឹកចំនួន ៤ កន្លែង
- សាងសង់បង្គន់អនាម័យចំនួន ២០ បង្គន់
- ផ្តល់ជ្រូកចំនួន ១០៤ ក្បាល
- ផ្តល់មេគោចំនួន ៣១ ក្បាល
- ផ្តល់មាន់ចិញ្ចឹមតាមគ្រួសារចំនួន ៧០៥ ក្បាល
- ជីកស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារចំនួន ៩៤ ស្រះ និងផ្តល់កូនត្រីចំនួន ១៧.៨០០ ក្បាល
- ផ្តល់ពូជពោតក្រហមចំនួន ២០០ការ៉ុង
- ផ្តល់កូនក្រូចថ្លុងផ្អែម ចំនួន ៦៥៧ ដើម
- ផ្តល់ដើមឈើហូបផ្លែគ្រប់ប្រភេទចំនួន ៥ ៦៩៨ ដើម
- ជួសជុលផ្លូវក្នុងភូមិប្រវែង ៦០០ ម៉ែត្រ
- ផ្តល់សម្ភារៈសម្រាប់ធ្វើរោងជីកំប៉ុស្តិ៍ចំនួន ២៤០ កន្លែង សម្រាប់ ២៤០ គ្រួសារ
- ចែកសម្ភារៈកសិកម្មមួយចំនួនរួមមាន រនាស់ដៃ ចបកាប់ បង្គី ធុងស្រោចទឹក កៅស៊ូផ្លាស្ទិក កំបោរស ស្លឹកប្រក់ដំបូលដល់គ្រួសារចំនួន ៣០០ គ្រួសារ
- ផ្តល់ពូជបន្លែចម្រុះ ចំនួន ៩៣៧ គ្រួសារ ។

## ២.៦ ការអភិវឌ្ឍជនជាតិដើមភាគតិច

ការងារអភិវឌ្ឍជនជាតិដើមភាគតិច មានគោលបំណងធ្វើយ៉ាងណាឲ្យជនជាតិដើមភាគតិច មានជីវភាពរស់នៅសមរម្យ និងចាកផុតពីភាពក្រីក្រ អភិរក្ស និងការពារវប្បធម៌របស់ជនជាតិដើមភាគតិច ឲ្យបានគង់វង្ស ។ គោលដៅចំបងរបស់ក្រសួងគឺ ÷

- ជួយសហគមន៍ជនជាតិដើមភាគតិចមានការទទួលស្គាល់ដោយច្បាប់
- ជួយលើកកម្ពស់ជីវភាពជនជាតិដើមភាគតិចឲ្យកាន់តែប្រសើរឡើង
- ជួយថែរក្សាវប្បធម៌ប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចឲ្យបានគង់វង្ស

លទ្ធផលដែលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ ២០០៩ - ២០១៣ មានដូចខាងក្រោម÷

- *កំណត់អត្តសញ្ញាណ វប្បធម៌ប្រពៃណីជនជាតិដើមភាគតិច នៅខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ ស្ទឹងត្រែង បាត់ដំបង និង ខេត្តព្រះវិហារ និងបានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍បានចំនួន ៩៥ សហគមន៍*
- *ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិចបានចំនួន ១០ លើក ដែលក្នុងនោះ ថ្នាក់ជាតិ ២ លើក និងថ្នាក់ខេត្តបាន ៨ លើក*
- *រៀបចំអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកនៅថ្ងៃទី ០៩ ខែ សីហា បានចំនួន ៩ ដង គឺៈ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តពោធិសាត់ ខេត្តស្ទឹងត្រែង ព្រះសីហនុ និងខេត្តកំពង់ចាម ។*

## ២.៧ ការអភិវឌ្ឍវិស័យផ្លូវជនបទ÷

ផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជាមានប្រវែងប្រមាណជា ៤០ ០០០ គម ដែលគ្របដណ្តប់ជាង ៧២% នៃបណ្តាញផ្លូវជនបទទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ហើយដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។ ផ្លូវជនបទទាំងនោះមានការតភ្ជាប់÷

- ពីផ្លូវជាតិ ឬផ្លូវខេត្តទៅកាន់ទីប្រជុំជនក្រុង ស្រុក ខណ្ឌ
- ពីទីប្រជុំជនក្រុង ស្រុក ខណ្ឌ ទៅកាន់ទីប្រជុំជនក្រុង ស្រុក ខណ្ឌ
- ពីទីប្រជុំជនក្រុង ស្រុក ខណ្ឌ ទៅកាន់ទីប្រជុំជន ឃុំ សង្កាត់
- ពីទីប្រជុំជនឃុំ សង្កាត់ទៅកាន់ទីប្រជុំជនឃុំ សង្កាត់
- ពីទីប្រជុំជនឃុំ សង្កាត់ ទៅកាន់ភូមិ និងផ្លូវដែលតភ្ជាប់ពីភូមិ ទៅភូមិ និងផ្លូវក្នុងភូមិ ។

ក្នុងការអនុវត្តផែនការ ៥ ឆ្នាំ ២០០៩ - ២០១៣ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាបានចំណាយថវិកាជាច្រើនដើម្បីសាងសង់ កែលម្អ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ។ សមិទ្ធផលដែលក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបានមានដូចខាងក្រោម÷

- *កំពុងរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេសសម្រាប់ដាក់ក្នុងបញ្ជី Database ធ្វើផែនទីផ្លូវជនបទ ដើម្បីធ្វើការគ្រប់គ្រង ជួសជុល កែលម្អ និងថែទាំ*
- *សាងសង់ផ្លូវក្រាលក្រួសក្រហមបានចំនួន ២ ៥៨៧,៨៩ គម*

- *ផ្លូវជុល និងថែទាំផ្លូវជនបទ ក្រាលក្រួសក្រហមបានប្រវែង ៣ ៩៥៤,៩៥ គម*
- *ផ្លូវជនបទក្រាលកៅស៊ូប្រភេទ DBST ប្រវែង ១៩,៩០ គម និងបន្តសាងសង់លើប្រវែងផ្លូវ ៥០៥,៤០ គម ទៀតដែលសម្រេចបាន ៧០% ហើយគិតត្រឹម ឆ្នាំ ២០១៣ ។ ផ្លូវក្រាលកៅស៊ូមាននៅ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិសាត់ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ*
- *ផ្លូវក្រាលបេតុងសម្រេចបានប្រវែង ២៣,១ គម*
- *សាងសង់ស្ពានបេឡេត៍បានប្រវែង ១៤១ ម ស្ពានបេតុងបានប្រវែង ៧ ៥៩៤ ម និងលូគ្រប់ប្រភេទបានចំនួន ២ ៧៦៦ កន្លែង ។*

## ២.៨ ការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកជនបទ

បញ្ហាផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទគឺជាប្រធានបទមួយមានសារៈសំខាន់ដែលរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជនបានរួមគ្នាខិតខំដោះស្រាយយ៉ាងសកម្ម ដើម្បីធ្វើយ៉ាងណាសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា " ឆ្នាំ ២០១៥ សម្រេចផ្តល់ទឹកដែលមានការកែលម្អឱ្យដល់ប្រជាពលរដ្ឋជនបទឱ្យបាន ៥០% និង ១០០% នៅឆ្នាំ ២០២៥ " ។

ក្រសួងអភិវឌ្ឍន៍ជនបទ ជាស្ថាប័នតែមួយគត់ដែលទទួលខុសត្រូវលើវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ ដោយដើរតួជាអ្នកសម្របសម្រួលផង និងជាអ្នកអនុវត្តផង ត្រួតពិនិត្យ និងវាយតម្លៃផងក្នុងក្របខណ្ឌបច្ចេកទេស និងច្បាប់គតិយុត្ត ។ យោងតាមតារាងវាយតម្លៃសូចនាករលើវិស័យផ្គត់ផ្គង់ទឹកជនបទឆ្នាំ ២០១២ ក្រសួងបានសម្រេចចំនួន ៤២,០០ %ហើយ ។ មានសកម្មភាពជាច្រើនដែលក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តលើវិស័យទឹកស្អាតជនបទដែលសម្រេចបានលទ្ធផលដូចខាងក្រោម ÷

- *រៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ២០១៤ - ២០២៥*
- *ចងក្រងគោលការណ៍ណែនាំបទដ្ឋានបច្ចេកទេសនានាសម្រាប់អនុវត្ត*
- *រៀបចំផែនការយុទ្ធសាស្ត្រអាសេនិចឆ្នាំ ២០១១ - ២០១៥ សម្រាប់អនុវត្តក្នុងខេត្តទាំង ០៧ ដែលងាយរងគ្រោះដោយអាសេនិច*
- *សិក្សារៀបចំផែនទីទឹកក្រោមដីបានចំនួន ០៨ ខេត្ត គឺ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម និងជាយរាជធានីភ្នំពេញ*
- *រៀបចំគោលការណ៍ណែនាំបន្សុទ្ធទឹក និងស្តុកទឹកតាមគ្រួសារឱ្យមានសុវត្ថិភាព*

- *សាងសង់អណ្តូងស្នប់បាន* *១០ ៦៧៨ អណ្តូង*
- *សាងសង់អណ្តូងចម្រុះបាន* *១ ១៣២ អណ្តូង*
- *សាងសង់អណ្តូងលូបាន* *២៧៦ អណ្តូង*
- *ជួសជុលអណ្តូងស្នប់បាន* *៤ ១២២ អណ្តូង*
- *ជួសជុលអណ្តូងលូ និងអណ្តូងចម្រុះបាន* *១ ៩១៧ អណ្តូង*
- *ស្តារស្រះសហគមន៍បាន* *២២ ស្រះ*
- *សាងសង់ស្រះសហគមន៍បាន* *១៩២ ស្រះ*
- *សាងសង់អាងត្រងទឹកភ្លៀងបាន* *៣ ៥៤០ អាង*
- *សាងសង់ប្រព័ន្ធចែកចាយទឹកតាមទុយោបាន* *០៦ ប្រព័ន្ធ*

## ២.៩ ការអភិវឌ្ឍវិស័យអនាម័យជនបទ

ទស្សនៈវិស័យនៃការលើកកម្ពស់អនាម័យជនបទ បានបង្ហាញថានៅឆ្នាំ ២០១៥ ប្រជាពលរដ្ឋជនបទ ៣០% និងនៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋជនបទ ១០០% នឹងទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាព និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យល្អ ។ ក្នុងការអនុវត្តជាក់ស្តែងក្នុងឆ្នាំ ២០១២ វិស័យអនាម័យជនបទសម្រេចបានជាង ៣៣% ហើយ ( លើសសូចនាករដែលបានគ្រោងទុក ) ។ ទិសដៅចម្បងសម្រាប់អភិវឌ្ឍវិស័យលើកកម្ពស់អនាម័យជនបទគឺ ដើម្បីផ្លាស់ប្តូរតួនាទីស្ថាប័នថ្នាក់កណ្តាលពីការអនុវត្តដោយខ្លួនឯងទៅជាការសម្របសម្រួល និងសហប្រតិបត្តិការឱ្យ សហគមន៍ចូលរួមអនុវត្តវិញ ព្រមទាំងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ធ្វើសមាហរណកម្មគោលនយោបាយជាតិ និងយុទ្ធសាស្ត្រជាតិនៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទៅក្នុងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់កម្មវិធីថ្នាក់ក្រោមជាតិ ។ សកម្មភាពសំខាន់ៗលើកម្មវិធីលើកកម្ពស់អនាម័យជនបទរួមមាន÷

- *ចុះសិក្សា និងប្រមូលទិន្នន័យ*
- *បង្កើត និងបណ្តុះបណ្តាលអ្នកសម្របសម្រួលអនាម័យភូមិ*
- *ចុះអប់រំអនាម័យតាមភូមិ*
- *យុទ្ធនាការផ្សព្វផ្សាយអនាម័យ*
- *រៀបចំទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា*
- *ប្រជុំផ្លាស់ប្តូរបទពិសោធន៍*

- *ត្រួតពិនិត្យ និងតាមដានការអនុវត្ត*
- *ផលិតសម្ភារៈឧបទ្ទេសផ្សេងៗមានដូចជា ខិតប័ណ្ណ ផ្ទាំងរូបភាព សម្រាប់អប់រំអនាម័យ*
- *សាងសង់បង្គន់អនាម័យជាលក្ខណៈគ្រួសារបាន ៦៨ ៥០៨ បង្គន់ និងបង្គន់សាធារណៈ ៤២០ បង្គន់ ដែលគាំទ្រដោយថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍នានា*
- *អនុវត្តទីផ្សារអនាម័យនៅតាមបណ្តាខេត្តចំនួន ១០ គឺ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តក្រចេះ និង ខេត្តសៀមរាប* ។ ទីផ្សារអនាម័យគឺសំដៅដល់ការចូលរួមពីវិស័យឯកជនក្នុងការសាងសង់បង្គន់អនាម័យតាមផ្ទះដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួន ហើយបង្គន់ដែលប្រើប្រាស់មានតម្លៃថោកសមរម្យ និងមានគុណភាពល្អសម្រាប់សាងសង់ ។

## ៣-តារាងវាយតម្លៃសូចនាករដែលបានអនុវត្តក្នុង ផយអជ ២០០៩-២០១៣

នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (ផ.យ.អ.ជ) ២០០៩-២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទបានបញ្ចូលសូចនាករសំខាន់ៗចំនួន ៣ សម្រាប់ធ្វើការតាមដានការអនុវត្ត សូចនាករទាំង ៣ នេះមាន សូចនាករផ្លូវជនបទ សូចនាករទឹកស្អាត និងសូចនាករអនាម័យជនបទ ។

ក្នុងការអនុវត្តកន្លងមក សូចនាករផ្លូវជនបទពុំអាចសម្រេចគោលដៅតាមផែនការដែលបានគ្រោងទុកទេព្រោះមានកត្តាបីសំខាន់÷ ទី១.ការដាក់តួលេខសូចនាករខ្ពស់ពេកពុំអាចសម្រេចបាន ទី២. ក្នុងអំឡុងពេលអនុវត្តប្រទេសកម្ពុជាបានជួបនឹងវិបត្តិហិរញ្ញវត្ថុ និងគ្រោះទឹកជំនន់ ការប៉ះទង្គិចដោយអាវុធតាមព្រំដែនខ្មែរ-ថៃដែលធ្វើឱ្យខ្វះថវិកាសម្រាប់អនុវត្ត និងទី៣.ថវិកាមួយចំនួនបង្កើនលើការងារជួសជុលថែទាំផ្លូវច្រើនជាងការសាងសង់ផ្លូវថ្មី ដែលជាមូលហេតុនាំឱ្យតួលេខសូចនាករយឺតជាងផែនការដែលបានគ្រោងទុក ។

ចំពោះវិស័យទឹកស្អាតជនបទដែលប្រជាពលរដ្ឋជនបទបានទទួលរយៈពេល ៥ ឆ្នាំកន្លងទៅនេះមានការកើនឡើងពី ៤០,៤៩% ដល់ ៤៣,២០%នៅឆ្នាំ ២០១១ និងឆ្នាំ ២០១២ មានចំនួនតែ ៤២,០០%ប៉ុណ្ណោះ ។ តាមពិតតួលេខទឹកស្អាតជនបទបានគ្របដណ្តប់ដល់ទៅជិត ៤៧% ទៅហើយ (បើគិតតាមនិយមន័យចាស់)តែដោយមានការសម្របសម្រួលបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ (WB,ADB) អង្គការ UNICEF ព្រមជាមួយក្រសួងផែនការតាមរយៈវិទ្យាស្ថានជាតិស្ថិតិ (NIS) បានផ្លាស់ប្តូរនិយមន័យទឹកស្អាតថ្មី (ទឹកដែលមានសុវត្ថិភាព) ដោយបន្ថែមឧបករណ៍មួយចំនួនទៀតទៅលើប្រភពទឹក ។ ឧទាហរណ៍ អណ្តូងល្អដែលមានគម្របត្រឹមត្រូវ មានចាក់ខឿនបេតុងស្អាតជុំវិញមានអនាម័យល្អ

សាងសង់ស្ថិតនៅឆ្ងាយពីបង្គន់អនាម័យ ហើយត្រូវបានដាំទឹកឱ្យពុះ ឬឆ្លងកាត់ឧបករណ៍ធុងចម្រោះមុននឹងយកមកបរិភោគ ទើបចាត់ទុកជាទឹកមានសុវត្ថិភាព ។ មូលហេតុនេះ ហើយបានជាសូចនាករទឹកស្អាតបានធ្លាក់ចុះមកវិញត្រឹម ៤២%នៅឆ្នាំ ២០១២ កន្លងទៅនេះ ។ ដូចនេះវិស័យទឹកស្អាតជនបទនៅខ្វះ ៨ % ទៀតទើបអាចសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១៥ បាន ។ ដូច្នេះយើងត្រូវបង្កើនថវិកាពីរដងនៃថវិកាប្រចាំឆ្នាំបច្ចុប្បន្ន និងត្រូវការការជួយគាំទ្រថវិកាបន្ថែមទៀតពីដៃគូ និងអង្គការនានាក្នុងវិស័យទឹកស្អាតទើបអាចសម្រេចគោលដៅ ៥០%នៅឆ្នាំ ២០១៥ បាន ។

ចំពោះវិស័យអនាម័យជនបទវិញ មានវឌ្ឍនភាពយ៉ាងខ្លាំងបើពិនិត្យលើសូចនាករផែនការ និងសូចនាករគោលដៅដែលយើងសម្រេចបាន ។ ពីឆ្នាំ ២០០៨ យើងមានតែ ២៣,២៤ % ( Baseline ) ក្នុងការអនុវត្តជាក់ស្តែងរហូតដល់ឆ្នាំ ២០១២ យើងទទួលបានដល់ទៅជាង ៣៣ % រួចទៅហើយ ។ ដូច្នេះវិស័យអនាម័យជនបទមានវឌ្ឍនភាពកើនឡើងលើសគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដល់ទៅជាង ៣ % រួចទៅហើយក្នុងឆ្នាំ ២០១២ កន្លងទៅនេះ ។ ប្រការដែលវិស័យអនាម័យមានការរីកចម្រើនខ្លាំងដោយសារប្រជាពលរដ្ឋជនបទមានការយល់ដឹងពីអនាម័យច្រើនតាមរយៈការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ ទូរទស្សន៍ ក្រុមការងារផ្សព្វផ្សាយអនាម័យតាមភូមិ និងទិវាអនាម័យប្រចាំឆ្នាំជាដើម ។ គួបផ្សំនឹងកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការកើនឡើងផងដែរ ដែលបានធ្វើឱ្យប្រជាពលរដ្ឋនៅតាមសហគមន៍ជនបទមានការចូលរួមយ៉ាងច្រើន ដែលជាមូលហេតុជំរុញឱ្យវិស័យអនាម័យមានការកើនឡើងយ៉ាងឆាប់រហ័ស ។

តារាងខាងក្រោមនេះ ធ្វើការប្រៀបធៀបលទ្ធផលនៃការអនុវត្តធៀបនឹងផែនការ ÷

| **Indicator**<br>**សូចនាករ** | ផែនការ/<br>អនុវត្តបាន | 2008<br>Baseline | 2009 | 2010 | 2011 | 2012 |
|---|---|---|---|---|---|---|
| ប្រវែងផ្លូវជនបទដែលបានស្តារ (ធៀបនឹងប្រវែងផ្លូវជនបទសរុបប្រវែង ៤០.០០០ គម)<br>Rehabilitation of Rural Roads (out of the total rural roads of 40,000 Km) | ផែនការ (គម) | 24,140 | **25,658** | 26,658 | 27,658 | 28,658 |
| | អនុវត្តបាន (គម) | 24,484.89 | 25,236.89 | 25,686.07 | 26,293.87 | 26,900.56 |
| ភាគរយនៃប្រជាពលរដ្ឋជនបទ ទទួលបានការផ្គត់ផ្គង់ទឹកជនបទដែលមានការកែលម្អ<br>Access to improved rural water supply-% of Rural Population | ផែនការ (%) | 40.49 | 41.99 | 43.49 | 44.99 | 46.49 |
| | អនុវត្តបាន (%) | 40.49 | 42.20 | 41.10 | 43.20 | 41.90 |

| | | | | | | |
|---|---|---|---|---|---|---|
| ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់អនាម័យដែលមានការកែលម្អ Access to improved sanitation -% of Rural Population | ផែនការ (%) | 23.24 | 24.24 | 25.00 | 27.00 | 29.00 |
| | អនុវត្តបាន (%) | 23.24 | 23.00 | 29.20 | 33.20 | 33.30 |

ចំពោះសូចនាករវាយរងផ្សេងៗទៀត ដែលជួយគាំទ្រដល់ការអនុវត្តគោលនយោបាយរបស់ក្រសួងពិសេសផ្នែកទន់ (Software) ក្រសួងបានទទួលជោគជ័យតាមផែនការដែលបានកំណត់ហើយ ។ តែក្រសួងក៏ត្រូវបន្តអនុវត្តនៅនីតិកាលទី ៥ នៃរដ្ឋសភានេះបន្តទៀត នូវសកម្មភាពមួយចំនួនដើម្បីធានាដល់និរន្តរភាព និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរបស់ក្រសួងឲ្យទទួលបានជោគជ័យ ។

## ៤-បញ្ហាប្រឈមលើវិស័យអភិវឌ្ឍន៍ជនបទ

ទោះបីជាមានការរីកចម្រើនលើគ្រប់វិស័យក៏ដោយក៏ការអនុវត្ត ផ.យ.អ.ជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់ក្រសួងបានជួបបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម÷

- សម្ភារៈ ទំនិញ និងប្រេងឥន្ធនៈមានការឡើងថ្លៃជាលំដាប់ដែលបានប៉ះពាល់ដល់តម្លៃគម្រោង
- ការបម្រែបម្រួលអាកាសធាតុដែលធ្វើឲ្យប៉ះពាល់ដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
- កំណើនយានយន្ត ការដឹកលើសទម្ងន់កំណត់ និងបើកលើសល្បឿនកំណត់ធ្វើឲ្យផ្លូវជនបទឆាប់ខូច និងមានគ្រោះថ្នាក់ចរាចរណ៍កើនឡើងជាញឹកញាប់
- ខ្វះការចូលរួមថែទាំផ្លូវជនបទពីថ្នាក់សហគមន៍ និងអ្នកប្រើប្រាស់ផ្លូវ
- ការយល់ដឹងពីអនាម័យនៅតាមជនបទនៅមានកម្រិត
- ការចូលរួមថែទាំអណ្តូងទឹក ស្រះទឹកពីសហគមន៍នៅមានកម្រិត
- ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋជនបទបានធ្វើឲ្យមានការខ្វះកម្លាំងពលកម្មនៅតំបន់ជនបទ
- ធនធានមនុស្សសម្រាប់បម្រើការអភិវឌ្ឍនៅមានកម្រិត
- ថវិកាដែលរដ្ឋបានផ្តល់ជូននៅមានកម្រិត
- ការវិភាជន៍ថវិកាសម្រាប់វិស័យសំខាន់ៗ (ទឹកស្អាត និងអនាម័យ) ពុំទាន់សមស្របនឹងការរីកចម្រើនរបស់ប្រទេស ( ប្រជាពលរដ្ឋមានការកើនឡើងតែថវិកាពុំមានការកើនឡើងទេ )។

## ៥-វិធានការដោះស្រាយ

ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ក្នុងនីតិកាលទី ៥ របស់រដ្ឋសភាឲ្យទទួលបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាឱ្យមានគណនេយ្យភាពនិងប្រសិទ្ធភាពតាមរយៈ ការបង្កើតអង្គភាពថវិកាសម្រាប់អនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ ២០១៥
- ជំរុញការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស
- បញ្ចូលបច្ចេកទេសថ្មីៗបន្ថែមទៀតទាក់ទងនឹងការបម្រែបម្រួលអាកាសធាតុក្នុងគម្រោងសាង សង់ផ្លូវជនបទ
- កែលម្អកម្រាលផ្លូវជនបទពីក្រួសក្រហមទៅជាកៅស៊ូពីរជាន់ DBST ឬ បេតុង
- ជំរុញឱ្យសហគមន៍ចូលរួមថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទមាន ផ្លូវ អណ្តូងទឹក ស្រះទឹកជាដើម
- ជំរុញបង្កើនល្បឿនការផ្គត់ផ្គង់ទឹកជនបទទ្វេដង ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជា ឆ្នាំ ២០២៥
- ចលនាឱ្យប្រជាពលរដ្ឋជនបទស្វែងរកចំណេះដឹងវិជ្ជាជីវៈមូលដ្ឋានណាមួយដើម្បីបង្កើតប្រាក់ ចំណូលក្នុងគ្រួសារតាមរយៈការបណ្តុះបណ្តាលជំនាញមូលដ្ឋាននៅតាមជនបទ
- បង្កើនការផ្តល់ឥណទានខ្នាតតូចជូនសហគ្រាសខ្នាតតូច និងមធ្យមនៅតាមជនបទ
- ជំរុញអ្នកវិនិយោគទុនឱ្យបង្កើតរោងចក្រ សហគ្រាសខ្នាតតូច និងមធ្យម ឬកសិ-ឧស្សាហកម្មនៅ តាមតំបន់ជនបទដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក និងបង្កើតការងារនៅតាមជនបទ ។

## ៦-សេចក្តីសន្និដ្ឋាន

រយៈពេល ៥ ឆ្នាំ ក្នុងនីតិកាលទី ៤ នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំប្រឹងប្រែងយ៉ាង ខ្លាំងហើយបានធ្វើឱ្យសម្រេចនូវសមិទ្ធផលយ៉ាងច្រើនក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដូចបានអធិប្បាយខាង លើ ។ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទមានការប្រែប្រួលយ៉ាងច្រើន ដែលគេអាច សង្កេតឃើញថា មានបណ្តាញទំនាក់ទំនងផ្លូវគមនាគមន៍ចូលទៅដល់ជនបទដាច់ស្រយាលដោយងាយ ស្រួលគ្រប់ច្រកល្ហកដែលអាចឱ្យប្រជាពលរដ្ឋប្រកបមុខរបរចិញ្ចឹមជីវិត ធ្វើដំណើរទៅមន្ទីរពេទ្យទាន់ពេល វេលា សិស្សានុសិស្សអាចទៅសាលារៀនគ្រប់ពេលវេលា អ្នកជំនួញអាចធ្វើពាណិជ្ជកម្មដោះដូរទំនិញ ដោយផ្ទាល់ជាមួយកសិករដោយកាត់បន្ថយពេលវេលា និងសោហ៊ុយធ្វើដំណើរដែលធ្វើឱ្យសកម្មភាព សេដ្ឋកិច្ចមានដំណើរការយ៉ាងល្អ ។ ចំពោះវិស័យទឹកស្អាត និងអនាម័យជនបទវិញប្រជាពលរដ្ឋមួយចំនួន ធំបានផ្លាស់ប្តូរឥរិយាបថមកប្រើប្រាស់ទឹកស្អាត ឬដាំទឹក ឬចម្រោះទឹកដោយធុងចម្រោះសម្រាប់បរិភោគ និងប្រើប្រាស់បង្គន់អនាម័យជាបណ្តើរៗហើយ ។ ប្រការនេះបានជួយដល់សុខភាពរបស់ប្រជាពលរដ្ឋ

យ៉ាងច្រើន និងកាត់បន្ថយចំណាយបានមួយភាគធំលើសេវាសុខភាពដែលបានជួយរក្សាកំណើនប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋជនបទ ។

ម៉្យាងទៀតបើសង្កេតជារួមតំបន់ជនបទ ដែលស្ថិតនៅក្បែរទីប្រជុំជនមានការផ្លាស់ប្តូរផ្ទះសម្បែងពីជញ្ជាំងប្រក់ស្លឹកមកជាប្រក់ស័ង្កសី ខ្លះប្តូរពីដំបូលប្រក់ស័ង្កសីមកជាដំបូលប្រក់ក្បឿង និងមានជញ្ជាំងរៀបឥដ្ឋស៊ីម៉ង់ត៍មួយចំនួនហើយដែរ ។ ចំនួនអ្នកមានម៉ូតូជិះ និងទូរទស្សន៍ពណ៌ ទូរស័ព្ទដៃកាន់តែកើនឡើងច្រើននៅតំបន់ជនបទដោយសារតែមានចរន្តអគ្គិសនីបានចូលទៅដល់ជាបណ្តើរៗហើយ ។ ចំណែកឯប្រាក់ចំណូលក្នុងម្នាក់ៗបានកើនដល់ជាង ១,០០០ ដុល្លារអាមេរិកហើយក្នុងឆ្នាំ ២០១៣ ។ ភាពក្រីក្របានធ្លាក់មកនៅក្រោម ១៩.៨០ % ក្នុងឆ្នាំ ២០១១ ក្នុងទូទាំងប្រទេស ។

## ក្រាហ្វិចនិន្នាការអត្រាភាពក្រីក្រនៅកម្ពុជា ពីឆ្នាំ២០០៧-២០១១




| | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|
| Cambodia | 47.8 | 29.9 | 22.9 | 21.1 | 19.8 |
| Phnom Penh | 19.1 | 13.6 | 12.8 | 12.4 | 10.9 |
| Other Urban Areas | 41 | 30.5 | 19.2 | 17 | 22.5 |
| Rural Areas | 53.2 | 31.9 | 24.6 | 22.7 | 20.7 |

## ផែនទី អត្រាភាពក្រីក្រតាមបណ្តារាជធានី ខេត្ត សម្រាប់ ឆ្នាំ ២០១១




ប្រភព: ក្រសួងផែនការ

# ផ្នែកទី២

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ

# (ផយអជ) ឆ្នាំ ២០១៤-២០១៨




យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

## ១-សេចក្តីផ្តើម

នីតិកាលទី ៤ នៃរដ្ឋសភាបានបិទបញ្ចប់ក្រោយការបោះឆ្នោតថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ ហើយនីតិកាលទី ៥ នៃរដ្ឋភាបានចាប់ផ្តើមឡើងក្នុងរយៈពេល ៥ ឆ្នាំទៀតគឺ ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ ។ រយៈពេល ៥ ឆ្នាំ នៃអណត្តិទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងកម្លាំងចិត្តក្នុងការរុញនាវាកម្ពុជាឆ្ពោះទៅរកវឌ្ឍនភាព និងសុភមង្គល វិបុលសុខជូនប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស ។

សមិទ្ធផលធំៗដែលរាជរដ្ឋាភិបាលសម្រេចបាននោះគឺ ប្រជាពលរដ្ឋទទួលបានសុខសន្តិភាពពេញលេញ និងកំពុងធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ កិច្ចអភិវឌ្ឍប្រទេសមានសន្ទុះកាន់តែខ្លាំងក្លាគ្រប់វិស័យ ពិសេសវិស័យទេសចរណ៍ កសិកម្ម ឧស្សាហកម្ម និងសេវាកម្មដែលជាវិស័យឈានមុខគេក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិឲ្យដល់ជាង ៧ % ក្នុងឆ្នាំ ២០១២ កន្លងទៅនេះ ។ ស្ថានភាពក្រីក្រនៅទូទាំងប្រទេសបានធ្លាក់ចុះពី ៤៧,៨០ % នៅឆ្នាំ ២០០៧ មកក្រោម ១៩,៨០ % នៅក្នុងឆ្នាំ ២០១១ កន្លងទៅនេះ និងកំពុងបន្តធ្លាក់ចុះដូចការព្យាករណ៍របស់រាជរដ្ឋាភិបាលប្រមាណជាង ១% ក្នុង ១ ឆ្នាំ ។ ចំណែកឯប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗបានកើនយ៉ាងឆាប់រហ័សដល់ជាង ១,០០០ ដុល្លារអាមេរិកក្នុងមួយនាក់ក្នុងមួយឆ្នាំ (ឆ្នាំ ២០១៣ ) ។ ប្រការនេះបានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសកម្ពុជាកំពុងរើខ្លួនចាកចេញពីប្រទេសដែលមានចំណូលទាបមកជាប្រទេសដែលមានចំណូលកមធ្យមកម្រិតទាប ។ នៅលើឆាកអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជាមានទំនាក់ទំនងល្អជាមួយបណ្តាប្រទេសជិតខាង ពិសេសបណ្តាប្រទេសក្នុងតំបន់អាស៊ាន និងបណ្តាប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗជាច្រើនមានសហរដ្ឋអាមេរិក សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និងសហព័ន្ធរុស្ស៊ីជាដើម ដែលនាំមកនូវការវិនិយោគជាច្រើនទាំងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឧស្សាហកម្ម សេវាកម្ម និងការអភិវឌ្ឍធនធានមនុស្ស ។ល។ ដែលជាទុនវិនិយោគយ៉ាងធំក្នុងការជំរុញឲ្យសេដ្ឋកិច្ចកម្ពុជាបោះជំហានទៅមុខយ៉ាងលឿនក្នុងរយៈពេលចុងក្រោយនេះ ។ កិច្ចការអភិវឌ្ឍទាំងអស់នេះអាចសម្រេចទៅបានដោយសារប្រទេសកម្ពុជាមានសុខសន្តិភាព និងមានស្ថិរភាពនយោបាយល្អ ។ ទាំងនេះគឺជាផ្លែផ្កានៃការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ២ តាមរយៈផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៤ នៃរដ្ឋសភាដើម្បីធានាកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាក្នុងទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាយ៉ាងតិចជាង ១ % ក្នុងមួយឆ្នាំ និងកំណើនសេដ្ឋកិច្ចប្រមាណជាង ៧ %ក្នុងមួយឆ្នាំ ។

ទោះជាយ៉ាងណាក៏ដោយក៏លទ្ធផលខាងលើនេះ មិនអាចកាត់ចេញពីការអភិវឌ្ឍជនបទតាមរូបភាពចម្រុះបានដែរ ព្រោះថាវាជាយុទ្ធសាស្ត្រគន្លឹះដ៏ល្អបំផុតឈានទៅរកការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងជួយជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិខ្ពស់យ៉ាងឆាប់រហ័ស ដោយសារតែប្រជាពលរដ្ឋកម្ពុជាចំនួន ៨០,៥០% កំពុងរស់នៅតំបន់ជនបទ ហើយភាគច្រើននៃប្រជាពលរដ្ឋក្រីក្រស្ថិតនៅតំបន់ជនបទប្រមាណជាង ៨០ % និង ១៩% ផ្សេងទៀតកំពុងរស់នៅទីប្រជុំជននៃប្រទេសកម្ពុជា ។ ពួកគេកំពុងទទួលភោគផលនៃការវិនិយោគទុនទាំងអស់ខាងលើតាមរយៈធ្វើការជាកម្មករ កម្មការិនីក្នុងរោងចក្រនានា ជាផលិតករក្នុងវិស័យកសិកម្ម កសិឧស្សាហកម្ម និងសេវាកម្មជាដើម ។ ទោះបីជាសេដ្ឋកិច្ចកម្ពុជាមានសន្ទុះយ៉ាងនេះក៏ដោយក៏ភាពក្រីក្រនៅមានប្រមាណជាង ១៩ % ទៀតក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ បញ្ហាចំណាកស្រុកស្វែងរកការងារធ្វើ បញ្ហាបម្រែបម្រួលអាកាសធាតុ កង្វះទីផ្សារលក់ផលិតផល កង្វះបច្ចេកទេសកសិកម្មដែលជាកត្តាធ្វើឲ្យទិន្នផលទាបនៃផលិតផលកសិកម្ម បញ្ហាតម្លៃចរន្តអគ្គិសនីជនបទនៅមានតម្លៃខ្ពស់ បញ្ហាទឹកស្អាត និងអនាម័យជនបទ បណ្តាញហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រកសិកម្ម សេវាអប់រំសុខភាពជនបទនៅមានកម្រិតនៅឡើយ ។

ទាំងនេះជាបញ្ហាប្រឈមដែលត្រូវជម្នះបន្តទៀតនៅក្នុងនីតិកាលទី ៥ នៃរដ្ឋសភាខាងមុខនេះ ដើម្បីធានាសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យបានសមរម្យ ។ ការដោះស្រាយបញ្ហាខាងលើនេះបាន គឺជាចលករជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគទុនក្នុង និងក្រៅស្រុកឲ្យចូលរួមចំណែកកសាង និងអភិវឌ្ឍប្រទេសជាតិយើងបានយ៉ាងឆាប់រហ័ស ។

ដោយឡែកការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ជាការចាំបាច់មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេស ពិសេសប្រទេសកំពុងអភិវឌ្ឍដូចប្រទេសកម្ពុជាយើង ដើម្បីធានាបង្កើនទាំងគុណភាព និងបរិមាណការងារឲ្យទាន់ពេលវេលាតាមតម្រូវការទីផ្សារក្នុងស្រុកក៏ដូចជាក្រៅស្រុក ។ ប្រការនេះទាមទារឲ្យនិយោជិកមានចំណេះដឹង និងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការប្រកួតប្រជែងជាមួយនឹងទីផ្សារពលកម្មក្រៅប្រទេស ព្រោះថានៅឆ្នាំ ២០១៥ ខាងមុខនេះ ប្រទេសកម្ពុជានឹងធ្វើសមាហរណកម្មសេដ្ឋកិច្ចពេញលេញចូលក្នុងសហគមន៍អាស៊ាន ។ ដូចនេះប្រជាពលរដ្ឋក្រីក្រដែលកំពុងរស់នៅតំបន់ជនបទ គួរតែត្រូវបានទទួលចំណេះដឹងជំនាញវិជ្ជាជីវៈមូលដ្ឋានណាមួយច្បាស់លាស់ដើម្បីបង្កើនប្រាក់ចំណូលសមរម្យក្នុងជីវភាពរស់នៅរបស់ពួកគេ ។ ការបង្កើនការផលិតក្នុងស្រុកប្រកបដោយគុណភាព និងបរិមាណសមស្របតាមតម្រូវការទីផ្សារ ទាមទារនូវការបញ្ចូលបច្ចេកទេសជំនាញវិជ្ជាជីវៈច្បាស់លាស់ពិតប្រាកដ ការគ្រប់គ្រងបានល្អ និងមានផែនការផលិតកម្មច្បាស់លាស់ ។

ការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិដើម្បីទទួលខុសត្រូវលើការធ្វើផែនការផលិតកម្ម

ការគ្រប់គ្រងអាជីវកម្មដោយខ្លួនឯងត្រូវបានក្រសួងគាំទ្រ និងជួយជំរុញដើម្បីធ្វើវិមជ្ឈការដល់ថ្នាក់សហគមន៍ ។ ការអប់រំប្រជាពលរដ្ឋតាមសហគមន៍ជនបទឱ្យយល់ដឹងពីការថែទាំសុខភាពអនាម័យ និងបរិភោគទឹកស្អាតជាប្រចាំដោយខ្លួនឯង ជាកត្តាសំខាន់ណាស់ក្នុងការបញ្ចៀសពីជំងឺដង្កាត់ផ្សេងៗដែលអាចឱ្យប្រជាពលរដ្ឋជៀសវាងពីការធ្លាក់ខ្លួនចូលក្នុងភាពក្រីក្របាន ។

## ២- ចក្ខុវិស័យ

ក្រសួងអភិវឌ្ឍន៍ជនបទមានចក្ខុវិស័យរយៈពេលវែងក្នុងការធ្វើយ៉ាងណាជួយជំរុញការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតំបន់ជនបទឱ្យធ្លាក់ចុះក្នុងកម្រិតអប្បរមា និងជំរុញកំណើនសេដ្ឋកិច្ចជនបទឱ្យប្រហាក់ប្រហែលទីប្រជុំជននៅឆ្នាំ ២០២៥ ។

## ៣-គោលបំណង និងគោលដៅ

### ៣.១-គោលបំណង

គោលបំណងរបស់ក្រសួងអភិវឌ្ឍន៍ជនបទគឺ ធ្វើឱ្យតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជាក្លាយជាតំបន់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងបរិស្ថានល្អដែលមានប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសន្តិភាព និងជីវភាពសមរម្យ ។

### ៣.២-គោលដៅ

គោលដៅចម្បងរបស់ក្រសួងអភិវឌ្ឍន៍ជនបទគឺ ជំរុញប្រសិទ្ធភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈឱ្យដល់ថ្នាក់មូលដ្ឋានតាមរយៈការជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ការអភិវឌ្ឍសហគមន៍ជនបទ ការផ្តល់ឥណទានជនបទ រួមនឹងវិស័យដទៃទៀតដើម្បីធ្វើឱ្យសម្រេចគោលបំណងខាងលើ ។

## ៤-គោលនយោបាយអភិវឌ្ឍន៍ជនបទ

ដើម្បីសម្រេចគោលបំណង និងគោលដៅខាងលើឱ្យទទួលបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតគោលនយោបាយចំនួនពីរ សម្រាប់ជាចក្ខុវិស័យរយៈពេលវែងគឺ÷

**គោលនយោបាយទី១** *÷ធានាលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទឱ្យមានតម្លាតខិតជិតទីប្រជុំជននៅឆ្នាំ២០២៥ ។*

**គោលនយោបាយទី២** *÷ជំរុញកំណើនសេដ្ឋកិច្ចជនបទតាមរយៈការអភិវឌ្ឍជនបទចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ ។*

គោលនយោបាយខាងលើ ត្រូវបានរៀបចំឡើងក្នុងបរិបទដែលប្រជាពលរដ្ឋទូទាំងប្រទេសកំពុងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងកិច្ចអភិវឌ្ឍប្រទេស ដែលបានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលវិជ្ជមានជាបន្តបន្ទាប់ ពិសេសមានការគាំទ្រពីបណ្តាប្រទេសជាមិត្តលើសកលលោក និងដៃគូអភិវឌ្ឍន៍នានាជាច្រើនក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា ។

បច្ចុប្បន្ននេះ ស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតំបន់ជនបទ មានការប្រែប្រួលយ៉ាងច្រើនក្នុងអំឡុងប៉ុន្មានឆ្នាំនេះ ដោយសង្កេតឃើញថា ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានប្រែក្លាយបន្តិចម្តងៗពីកម្រិតក្រីក្រ មកមានកម្រិតជីវភាពមធ្យម និងអ្នកមានកម្រិតជីវភាពមធ្យមកាន់តែធូរធារជាងមុន តាមរយៈការផ្តល់សេវាសាធារណៈជាច្រើនរួមមាន÷ ផ្លូវជនបទ ទឹកស្អាត អនាម័យ ជំនាញវិជ្ជាជីវៈផ្សេងៗ ការផ្តល់ឥណទានជនបទ ការអប់រំសហគមន៍ជនបទ អគ្គិសនីជនបទ សាលារៀន ប៉ុស្តិ៍ និងមណ្ឌលសុខភាព វត្តអារាម ប្រព័ន្ធធារាសាស្ត្រ ។ល។ ក្នុងគោលដៅបង្រួមគម្លាតរវាងអ្នកក្រ និងអ្នកមាន រវាងទីជនបទ និងទីប្រជុំជន ក្រសួងអភិវឌ្ឍន៍ជនបទនឹងខិតខំធ្វើឲ្យបានសម្រេចនៅឆ្នាំ ២០២៥ ខាងមុខនេះ ។ គោលនយោបាយទាំងពីរខាងលើនេះមានគោលបំណងដូចខាងក្រោម÷

**គោលបំណងគោលនយោបាយទី១÷**

- ធ្វើឲ្យប្រជាពលរដ្ឋក្នុងសហគមន៍ជនបទមានលទ្ធភាពរស់នៅដោយខ្លួនឯងប្រកបដោយចំណេះដឹងជំនាញវិជ្ជាជីវៈមូលដ្ឋានសមស្របដែលអាចបង្កើនប្រាក់ចំណូលប្រចាំគ្រួសារបាន
- ជំរុញឲ្យការវិនិយោគលើវិស័យកសិកម្ម និងមិនមែនកសិកម្ម សហគ្រាសខ្នាតតូច និងសហគ្រាសខ្នាតគ្រួសារដើម្បីបង្កើតការងារថ្មីៗបន្ថែមទៀតនៅតាមសហគមន៍ជនបទដែលមានសក្តានុពលរួចហើយដូចជាផ្លូវគមនាគមន៍ បណ្តាញអគ្គិសនី និងប្រភពធនធានដទៃទៀតដើម្បីកាត់បន្ថយចំណាកស្រុក និងបង្កើនប្រាក់ចំណូលបន្ថែមទៀត ។

**គោលបំណងគោលនយោបាយទី២÷**

- តភ្ជាប់ចរន្តសេដ្ឋកិច្ចពីជនបទដាច់ស្រយាលដែលជាតំបន់ផលិតកម្ម សេវាកម្ម ទេសចរណ៍មកកាន់ទីប្រជុំជន និងទីក្រុង ដើម្បីធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងផ្សេងៗតាមរយៈធ្វើឲ្យប្រសើរឡើងនូវបណ្តាញផ្លូវជនបទទាំងអស់នៅទូទាំងប្រទេស ។
- បន្តធ្វើឲ្យប្រសើរឡើងថែមទៀតនូវសេវាទឹកស្អាត និងអនាម័យជនបទដល់គ្រប់សហគមន៍ជនបទឲ្យបាន ១០០% នៅឆ្នាំ ២០២៥ និងជំរុញការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិចដើម្បីរក្សាភាសាប្រពៃណីល្អ វប្បធម៌ទំនៀមទម្លាប់របស់ជនជាតិដើម ។

## ៥-ទិសដៅនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ទិសដៅនយោបាយចុងក្រោយរបស់ក្រសួងអភិវឌ្ឍន៍ជនបទគឺ ធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទកាន់តែប្រសើរឡើង ដើម្បីធានាកាត់បន្ថយគម្លាតសេដ្ឋកិច្ចរវាងតំបន់ជនបទ ទីប្រជុំ និងទីក្រុង ទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ និងផ្នែករឹង ។

ដើម្បីសម្រេចទិសដៅនយោបាយនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់ទិសដៅអាទិភាពដូចខាងក្រោម÷

- **ទិសដៅទី១ ÷ ការកសាង និងលើកកម្ពស់សមត្ថភាព**
- **ទិសដៅទី២ ÷ ការស្តារ ថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ**
- **ទិសដៅទី៣÷ លើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជនបទឲ្យកាន់តែប្រសើរឡើង**

## ៦-បេសកកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

បេសកកម្មសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទមាន÷

- កៀរគរជំនួយសម្រាប់ការអភិវឌ្ឍជនបទ
- បណ្តុះបណ្តាលធនធានមនុស្សឲ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ចូលរួមចំណែកអភិវឌ្ឍន៍ជនបទ
- ពង្រីកការបណ្តុះបណ្តាលជំនាញមូលដ្ឋានជូនប្រជាពលរដ្ឋដើម្បីកាត់បន្ថយចំណាកស្រុក
- ធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទទូទាំងប្រទេស
- ពង្រីកការផ្តល់សេវាផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ជនបទ និងកែលម្អស្ថានភាពអនាម័យតាមសហគមន៍ជនបទឲ្យបានប្រសើរ
- អប់រំ ផ្សព្វផ្សាយអនាម័យជនបទ និងសាងសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋក្រីក្រ
- បណ្តុះបណ្តាល គ.អ.ភ ស្តីពីផែនការសកម្មភាពអភិវឌ្ឍន៍ភូមិឲ្យបានទូទាំងប្រទេស
- អភិវឌ្ឍតំបន់ព្រំដែនភាគខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា
- អភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ
- ការត្រៀមបង្ការគ្រោះភ័យ និងគ្រោះមហន្តរាយក្នុងសហគមន៍
- អភិវឌ្ឍសេដ្ឋកិច្ចជនបទ
- អភិវឌ្ឍជនជាតិដើមភាគតិច

## ៧-យុទ្ធសាស្ត្រអាទិភាព

ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់យុទ្ធសាស្ត្រអាទិភាពចំនួន ០៣ សម្រាប់អនុវត្តគោលនយោបាយទាំងពីរខាងលើ ។ យុទ្ធសាស្ត្រទាំងបីខាងក្រោមនេះកំពុងអនុវត្តក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ÷

អាទិភាពទី១ ៖ ពង្រឹងស្ថាប័ន និងអភិវឌ្ឍធនធានមនុស្ស

អាទិភាពទី២ ៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

អាទិភាពទី៣៖ លើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជនបទឲ្យកាន់តែប្រសើរឡើង

## ៨-ផែនការសកម្មភាព ២០១៤-២០១៨

ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ពិសេសការចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ក៏ដូចជាផែនការអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភាខាងមុខនេះឲ្យទទួលបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបានពិនិត្យកែលម្អផែនការសកម្មភាពមួយចំនួនឡើងវិញដើម្បីឲ្យសមស្របនឹងការវិវត្តថ្មីៗរបស់ប្រទេសកម្ពុជា ពិសេសការត្រៀមខ្លួនចូលរួមជាមួយសេដ្ឋកិច្ចក្នុងសហគមន៍អាស៊ាននៅឆ្នាំ ២០១៥ ខាងមុខក៏ដូចជាចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ ក្នុងឆ្នាំ ២០១៥ ដូចខាងក្រោម÷

### ទិសដៅទី១ ÷ ការកសាង និងលើកកម្ពស់សមត្ថភាព

- បន្តចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី ២និងទី ៣ ដោយជំរុញបង្កើតអង្គភាពថវិកា និងអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដោយពេញលេញ
- ចាប់ផ្តើមអនុវត្តកម្មវិធីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័តិមានវិទ្យា ( FMIS )
- បន្តធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល និងផែនការប្រចាំឆ្នាំ សម្រាប់ដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងកម្មវិធីនានារបស់ក្រសួង
- បន្តបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក និងខិតខំកៀរគររកជំនួយជួសជុល និងសាងសង់មន្ទីរការិយាល័យអភិវឌ្ឍន៍ជនបទស្រុកទាំង ២៤ រាជធានី ខេត្ត

- បន្តអនុវត្តគម្រោងផែនការមូលដ្ឋានចម្រុះ
- បន្តសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរួមចំណែកអភិវឌ្ឍន៍ជនបទ
- រៀបចំនិងដាក់ឱ្យប្រើប្រាស់ស្តង់ដារគណនេយ្យ
- បណ្តុះបណ្តាលពីវិធីសាស្ត្ររៀបចំបញ្ជីគណនេយ្យហិរញ្ញវត្ថុសម្រាប់អនុវត្តអង្គភាពថវិកា
- បន្តអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ
- បន្តរៀបចំ និងអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការដល់ថ្នាក់ក្រោមជាតិ
- គាំទ្រដំណើរការអនុវត្តវេទិកាសាធារណៈនៅតាមមូលដ្ឋាន
- អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- កសាងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីរាជការគ្រប់កម្រិត
- វាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលគ្រប់មន្ត្រីរាជការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងប្រជាពលរដ្ឋដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលក្នុងក្របខណ្ឌក្រសួង និងមជ្ឈមណ្ឌល
- ផ្សព្វផ្សាយការងារក្រសួងតាមរយៈទស្សនាវដ្តី និងព្រឹត្តប័ត្រព័ត៌មាន
- ជំរុញបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមូលដ្ឋានឱ្យបានគ្រប់ខេត្ត
- ជំរុញឱ្យបង្កើតមជ្ឈមណ្ឌល ឬវិទ្យាស្ថានជាតិអភិវឌ្ឍន៍ជនបទ
- អនុវត្តសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- អនុវត្តកម្មវិធីយេនឌ័រ ។

## ទិសដៅទី២ ៖ ការស្តារ ថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

- បន្តថែទាំ និងជួសជុលផ្លូវជនបទ និងសំណង់សិល្បការ
- បន្តកែលម្អផ្លូវជនបទពីកម្រាលក្រួសក្រហមទៅជាកម្រាលកៅស៊ូពីរជាន់ ឬបេតុង
- បន្តរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទឱ្យបានចប់សព្វគ្រប់ទូទាំង ២៥ ខេត្ត រាជធានី ដោយកំណត់អត្តសញ្ញាណផ្លូវជនបទ ធ្វើផែនទីផ្លូវជនបទ និងដាក់ស្លាកសញ្ញាចរាចរ
- ចាប់ផ្តើមសិក្សា និងសាកល្បងផ្លូវជនបទ និងសំណង់សិល្បការមួយចំនួនបន្សាំទៅនឹងការបម្រែបម្រួលអាកាសធាតុ ។

## ទិសដៅទី៣៖លើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជនបទឲ្យកាន់តែប្រសើរឡើង

- ការអភិវឌ្ឍភូមិចម្រុះ
- បញ្ជ្រាបការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងសហគមន៍ជនបទ

- បន្តបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ស្តីពីផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ
- ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចជនបទតាមរយៈវិធីសាស្ត្រចលនាភូមិថ្មី
- បន្តអភិវឌ្ឍភូមិតាមបណ្តោយព្រំដែនទិសខាងលិច និងទិសខាងជើងនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់ត្រីកោណកម្ពុជា វៀតណាម និងឡាវ ដែលជាតំបន់ប៉ូលសេដ្ឋកិច្ចទី៤
- បន្តអនុវត្តកម្មវិធីលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
- បន្តពង្រឹងសកម្មភាពរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទក្នុងខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តពោធិសាត់
- ជំរុញទីផ្សារផលិតផល សម្រាប់ប្រជាពលរដ្ឋក្រីក្រជនបទ
- បន្តពង្រឹងប្រតិបត្តិការសេវាឥណទានជូនប្រជាពលរដ្ឋក្រីក្រនៅជនបទ
- អភិវឌ្ឍអាជីវកម្ម និងសហគ្រាសខ្នាតតូច
- ជំរុញការសាងសង់មជ្ឈមណ្ឌលអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី
- បន្តរៀបចំសហគមន៍ជនជាតិដើមភាគតិច
- បន្តផ្គត់ផ្គង់ទឹកស្អាតដល់តំបន់ជនបទតាមរយៈជួសជុល ថែទាំ និងសាងសង់អណ្តូងទឹកគ្រប់ប្រភេទ ស្រះទឹក ពាងយក្ស ពិសេសជំរុញកសាងប្រព័ន្ធចែកចាយទឹកតាមទុយោនៅតំបន់ដែលមានប្រភពទឹកស្រាប់
- បង្កើតកម្មវិធីជាតិនៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលផ្តល់ធនធានថវិកាពីស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិហើយគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងអង្គការ NGOs
- បង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃថ្នាក់ជាតិសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងការរៀបចំកម្មវិធីជាតិ ស្តីពីការផ្លាស់ប្តូរទម្លាប់
- រៀបចំយុទ្ធសាស្ត្រថវិកាសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យដែលផ្តោតលើការជួយគាំទ្រគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ
- រៀបចំតួនាទីថ្នាក់ក្រោមជាតិជាពិសេសឃុំ-សង្កាត់ ស្រុក-ក្រុង ក្នុងការផ្តល់សេវាកម្មការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទស្របគ្នាជាមួយនឹងការអនុវត្តតាមគោលការណ៍ណែនាំ និងកម្មវិធីកសាងសមត្ថភាព
- បង្កើតកម្មវិធីជាតិផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង
- លើកកម្ពស់ការយល់ដឹងពីការការពារជំងឺអេដស៍

- បង្កើតគោលការណ៍ណែនាំស្ដីពីការឧបត្ថម្ភធន សម្រាប់ទឹកស្អាត និងអនាម័យដោយផ្ដោតជាពិសេសលើគ្រួសារក្រីក្រ និងងាយរងគ្រោះ
- បែងចែកតួនាទីដល់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ (ឃុំ និងស្រុក) ផ្នែកខាងការផ្ដល់សេវាពាក់ព័ន្ធជាមួយនឹងទឹក និងអនាម័យដោយមានផ្ដល់ឱ្យពួកគេនូវគោលការណ៍ណែនាំស្ដីពីការអនុវត្ត និងកម្មវិធីកសាងសមត្ថភាព
- បង្កើតកម្មវិធីសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងការគ្រប់គ្រងការផ្គត់ផ្គង់ទឹក នៅថ្នាក់ភូមិ
- បន្តជួសជុលសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូចដើម្បីផ្ដល់ទឹកសម្រាប់កសិកម្មខ្នាតតូចនិងមធ្យម
- បន្តអប់រំអំពីសុខភាព និងអនាម័យព្រមទាំងសាងសាង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋក្នុងសហគមន៍ជនបទ ។

## ៩-តម្រូវការធនធានសម្រាប់អនុវត្ត ផយអជ ឆ្នាំ ២០១៤-២០១៨

(ឯកតា ពាន់ដុល្លារ)

| លរ | ផែនការសកម្មភាព | ឯកតា | ចំនួន | 2014 | 2015 | 2016 | 2017 | 2018 | 2014-2018 |
|---|---|---|---|---|---|---|---|---|---|
| 1 | បន្តបណ្ដុះបណ្ដាលផែនការថវិកាកម្មវិធី | នាក់ | 600 | 40 | 40 | 40 | 40 | 40 | 200 |
| 2 | បច្ចុប្បន្នភាពផែនការមូលដ្ឋានចម្រុះ | ស្រុក | 4 | 25 | 25 | 25 | 25 | 25 | 125 |
| 3 | ត្រួតពិនិត្យតាមដាន និងវាយតម្លៃ | ខេត្ត | 25 | 30 | 30 | 30 | 30 | 30 | 150 |
| 4 | ការបណ្ដុះបណ្ដាលកុំព្យូទ័រ | នាក់ | 100 | 15 | 15 | 15 | 15 | 15 | 75 |
| 5 | ការរៀបទិន្នន័យផ្ដល់សេវាថ្នាក់ក្រោមជាតិ | នាក់ | 120 | 30 | 30 | 30 | 30 | 30 | 150 |
| 6 | ការផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាតាមកម្មវិធី | នាក់ | 120 | 30 | 35 | 40 | 40 | 40 | 185 |
| 7 | ការពង្រឹងសមត្ថភាព ការអនុវត្តវេជ្ជទេយ្យបុរេប្រទានកម្មវិធី | នាក់ | 120 | 30 | 35 | 40 | 40 | 40 | 185 |
| 8 | ការពង្រឹងសមត្ថភាពគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ | ខេត្ត | 25 | 30 | 35 | 40 | 40 | 40 | 185 |
| 9 | ការផ្សព្វផ្សាយលទ្ធផលសន្និបាត | ខេត្ត | 24 | 75 | 80 | 90 | 100 | 100 | 445 |
| 10 | ការផ្គត់ផ្គង់កុំព្យូទ័រសម្រាប់មន្ត្រីមន្ទីររាជធានី ខេត្ត | នាក់ | 650 | 250 | 250 | 250 | 250 | 250 | 1,250 |
| 11 | ផ្សព្វផ្សាយតួនាទីភារកិច្ចសវនកម្មផ្ទៃក្នុង | ខេត្ត | 5 | 13 | 13 | 13 | 13 | 13 | 65 |
| 12 | ពង្រឹងប្រតិបត្តិការសវនកម្មផ្ទៃក្នុង | មន្ទីរ | 24 | 77 | 80 | 85 | 90 | 90 | 422 |
| 13 | ពង្រឹងសមត្ថភាពជំនាញសវនកម្ម | នាក់ | 15 | 8 | 8 | 8 | 8 | 8 | 40 |
| 14 | បន្តការងារអធិការកិច្ចតាមមន្ទីរអភិវឌ្ឍន៍ជនបទ | ខេត្ត | 24 | 10 | 10 | 10 | 10 | 10 | 50 |
| 15 | ផ្សព្វផ្សាយផែនការអធិការកិច្ច | ខេត្ត | 24 | 20 | 20 | 20 | 20 | 20 | 100 |
| 16 | សិក្សា និងកំណត់អាទិភាពតម្រូវការបណ្ដុះបណ្ដាល | នាក់ | 450 | 30 | 30 | 30 | 30 | 30 | 150 |
| 17 | បណ្ដុះបណ្ដាលមន្ត្រីនៃមន្ទីរអភិវឌ្ឍន៍ជនបទ | នាក់ | 800 | 80 | 80 | 100 | 100 | 100 | 460 |
| 18 | ការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍធនធានមនុស្ស | នាក់ | 2000 | 120 | 150 | 150 | 150 | 150 | 720 |
| 19 | រៀបចំនិងផលិតព្រឹត្តប័ត្រព័ត៌មានរបស់ក្រសួង | ក្បាល | 20000 | 50 | 50 | 50 | 50 | 50 | 200 |
| 20 | បណ្ដុះបណ្ដាលជំនាញមូលដ្ឋានខេត្តព្រៃវែង | នាក់ | 2500 | 80 | 80 | 80 | 100 | 100 | 440 |
| 21 | បណ្ដុះបណ្ដាលជំនាញមូលដ្ឋានខេត្តស្វាយរៀង | នាក់ | 2500 | 80 | 80 | 80 | 100 | 100 | 440 |
| 22 | បណ្ដុះបណ្ដាលជំនាញមូលដ្ឋានខេត្តកំពង់ចាម | នាក់ | 1500 | 50 | 50 | 50 | 50 | 50 | 440 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 23 | បណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តបាត់ដំបង | នាក់ | 1500 | 50 | 50 | 50 | 50 | 50 | 440 |
| 24 | បណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តពោធិសាត់ | នាក់ | 1500 | 50 | 50 | 50 | 50 | 50 | 440 |
| 25 | ការបង្កើតមជ្ឈមណ្ឌលជាតិអភិវឌ្ឍន៍ជនបទ | នាក់ | 1000 | | 150 | 150 | 150 | 150 | 600 |
| 26 | ការងារបញ្ហាបយេនឌ័រ | | | 12 | 12 | 12 | 12 | 12 | 60 |
| 27 | លើកកម្ពស់សមត្ថភាពមន្ត្រីលើការងាររដ្ឋបាល | | | 15 | 32 | 32 | 32 | 32 | 143 |
| 28 | បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារក្នុងក្រសួង | | | 5 | 5 | 5 | 5 | 5 | 25 |
| 29 | វាយតម្លៃ និងកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច | | | 70 | 70 | 70 | 70 | 70 | 350 |
| 30 | សិក្សា និងអភិរក្ស នូវទំនៀមទំលាប់ជនជាតិដើមភាគតិច | | | 60 | 60 | 60 | 60 | 60 | 300 |
| 31 | ពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | 50 | 50 | 50 | 50 | 50 | 200 |
| 32 | រៀបចំអភិវឌ្ឍន៍សហគមន៍ចម្រុះជនជាតិដើមភាគតិច | | | 80 | 80 | 80 | 80 | 80 | 400 |
| 33 | ប្រារព្ធទិវាជនជាតិដើមភាគតិច | | | 75 | 75 | 75 | 75 | 75 | 375 |
| 34 | ថែទាំផ្លូវជនបទលក្ខណៈខួប និង ប្រចាំ | គម | | 24,000 | 26,400 | 29,040 | 31,944 | 35,138 | 146,522 |
| 35 | កែលំអផ្លូវពីកម្រាលក្រួសក្រហម ជាកម្រាលកៅស៊ូពីរជាន់ | | | 640 | 768 | 922 | 1,100 | 1,320 | 4,750 |
| 36 | ការរៀបចំបញ្ជីសារពើភណ្ឌផ្លូវ ផែនទីផ្លូវជនបទ និងការដាក់ស្លាកសញ្ញាចរាចរផ្លូវជនបទ | | | 212 | 233 | 256 | 282 | 308 | 1,291 |
| 37 | ការចូលរួមបន្សុំាការប្រែប្រួលអាកាសធាតុ និងបរិស្ថាន | | | 10,800 | 14,400 | 18,000 | 14,400 | 14,400 | 72,000 |
| 38 | ការសាងសង់អណ្តូង | | | 200 | 220 | 240 | 260 | 280 | 1,200 |
| 39 | ការជួសជុលអណ្តូង | | | 256 | 282 | 310 | 341 | 375 | 1,564 |
| 40 | ការជីកនិងស្តារស្រះសហគមន៍ | | | 187 | 205 | 225 | 247 | 272 | 1,136 |
| 41 | ការសាងសង់អាងត្រងទឹកភ្លៀង | | | 38 | 42 | 46 | 51 | 56 | 233 |
| 42 | ការសាងសង់ប្រព័ន្ធចែកចាយទឹក | | | 10 | 20 | 30 | 40 | 50 | 150 |
| 43 | ការសាងសង់និងស្តារប្រព័ន្ធធារាសាស្ត្រខ្នាតតូច | | | 18 | 20 | 20 | 20 | 20 | 98 |
| 44 | ការផ្តល់ធុងចម្រោះ | | | 7 | 10 | 10 | 10 | 10 | 47 |
| 45 | បណ្តុះបណ្តាលការប្រើប្រាស់និងស្តុកទឹកឲ្យមានសុវត្ថិភាពតាមគ្រួសារ | | | 20 | 20 | 20 | 20 | 20 | 100 |
| 46 | ការស្រង់ទិន្នន័យអណ្តូង | | | 10 | 10 | 10 | 10 | 10 | 50 |
| 47 | បង្កើតកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទក្រោមជំនួយថវិកាពីប្រភពថវិការបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា | | | 10 | 10 | 10 | 10 | 10 | 50 |
| 48 | បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនៅថ្នាក់ជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | | | 10 | 10 | 10 | 10 | 10 | 50 |
| 49 | បង្កើតកម្មវិធីសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងការគ្រប់គ្រងការផ្គត់ផ្គង់ទឹក នៅថ្នាក់ភូមិ | | | 10 | 10 | 10 | 10 | 10 | 50 |
| 50 | បង្កើតកម្មវិធីជាតិផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង | | | 5 | 5 | 5 | 5 | 5 | 25 |
| 51 | បង្កើតយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានសម្រាប់ទឹក និងអ | | | 10 | 10 | 10 | 10 | 10 | 50 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | នាម័យដោយផ្តោតជាពិសេសលើគ្រួសារក្រីក្រ និងងាយរងគ្រោះ | | | | | | | | |
| 52 | បែងចែកតួនាទីដល់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ) ឃុំ និងស្រុក (ផ្នែកខាងការផ្តល់សេវាពាក់ព័ន្ធជាមួយនឹងទឹកនិងអនាម័យដោយមានផ្តល់ឱ្យពួកគេនូវគោលការណ៍ណែនាំស្តីពីការអនុវត្ត និងកម្មវិធី កសាងសមត្ថភាព | | | 10 | 10 | 10 | 10 | 10 | 50 |
| 53 | ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍភូមិ | | | 150 | 200 | 250 | 300 | 350 | 1.250 |
| 54 | ការអភិវឌ្ឍភូមិចម្រុះ | | | 50 | 70 | 100 | 150 | 200 | 570 |
| 55 | ការបញ្ជ្រាបការយល់ដឹងស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ | | | 5 | 25 | 30 | 40 | 50 | 150 |
| 56 | ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ | | | 35 | 40 | 50 | 60 | 70 | 255 |
| 57 | ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ | | | 35 | 40 | 50 | 60 | 70 | 255 |
| 58 | ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ | | | 35 | 45 | 60 | 70 | 80 | 290 |
| 59 | រៀបចំបង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃ កម្មវិធីផ្គត់ផ្គង់ ទឹកស្អាតនិងអនាម័យជនបទ | | | 1,500 | 1,500 | 1,500 | 1,500 | 1,00 | 7,000 |
| 60 | ជំរុញការអនុវត្តអនាម័យក្នុងសហគមន៍ជនបទ | គ្រួសារ | 50,000 | 3,000 | 3,000 | 3,000 | 3,000 | 3,000 | 9,000 |
| 61 | រៀបចំបង្កើតយុទ្ធសាស្ត្រជាតិស្តីពីការផ្លាស់ប្តូរទម្លាប់និងការទំនាក់ទំនង | | | 1,000 | | | | | 1,000 |
| 62 | រៀបចំបង្កើត និងអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ | | | 1,000 | 1,500 | 1,500 | 1,500 | 1,500 | 7,000 |
| 63 | រៀបចំតួនាទីស្ថាប័នថ្នាក់ក្រោមជាតិ(ឃុំសង្កាត់ស្រុក ខណ្ឌ) ក្នុងការផ្តល់សេវាកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ តាមគោលការណ៍ណែនាំ និងកម្មវិធីកសាងសមត្ថភាព | | | 500 | | | | | 500 |
| 64 | បង្កើតបណ្តាញនិងកសាងសមត្ថភាពក្រុមសម្របសម្រួលអនាម័យភូមិ | នាក់ | 500.000 | 1,500 | 1,500 | 1,500 | 1,500 | 1,500 | 7,500 |
| 65 | សាងសង់បង្គន់អនាម័យ និងកន្លែងលាងដៃតាមសាលារៀននៅជនបទ | | | 2,000 | 2,000 | 2,000 | 2,000 | 2,000 | 10,000 |
| 66 | ការងារទីផ្សារ និងការផ្តល់គំនិតអាជីវកម្មខ្នាតតូច | | | 50 | 100 | 200 | 200 | 200 | 750 |
| 67 | ផ្តល់បទពិសោធន៍ជំនាញ និងបង្កើនមុខរបរអាជីវកម្មខ្នាតតូច | | | 180 | 360 | 720 | 720 | 720 | 2,700 |
| 69 | ពង្រឹងកិច្ចការរដ្ឋបាល និងកិច្ចការទូទៅ | | | 41 | 41 | 41 | 41 | 41 | 205 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 70 | ចុះតាមដាន និងត្រួតពិនិត្យការងាររដ្ឋបាល | | | 27 | 27 | 27 | 27 | 27 | 135 |
| 71 | ការប្រឡងជ្រើសរើស ក្របខ័ណ្ឌថ្មី | | | 11 | 11 | 11 | 11 | 11 | 44 |
| 72 | ការបង្កើនប្រាក់ចំណូលតាមរយៈកម្មវិធីសហគ្រិនភាពជនបទ | | | 1500 | 1000 | 1000 | 1000 | 1500 | 6000 |
| 73 | គម្រោងឥណទានសហគមន៍សម្រាប់អភិវឌ្ឍន៍ជនបទ | | | 370 | 600 | 1030 | 1000 | 1000 | 4000 |
| 74 | ការលើកកម្ពស់សេដ្ឋកិច្ចជនបទតាមរយៈការជំរុញទីផ្សារផលិតផលជនបទ | | | 1000 | 2000 | 1000 | 1000 | 1000 | 6000 |

## ១០-គម្រូវការធនធានសម្រាប់អនុវត្តផែនការវិនិយោគសាធារណៈ ឆ្នាំ ២០១៤-២០១៨

ឯកតា ពាន់ ដុល្លារ

| ល.រ | ឈ្មោះគម្រោង | 2014 | 2015 | 2016 | 2017 | 2018 | 2014-2018 |
|---|---|---|---|---|---|---|---|
| 1 | កែលម្អផ្លូវពីកម្រាលក្រួសក្រហមទៅជាកម្រាលកៅស៊ូ | 93,000 | 110,000 | 125,000 | 140,000 | 150,000 | 618,000 |
| 2 | សាងសង់ / ស្តារផ្លូវជនបទ និងសាងសង់សំណង់សិល្បការ | 60,000 | 80,000 | 100,000 | 120,000 | 140,000 | 500,000 |
| 3 | គម្រោងផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតជនបទ | 19,400 | 19,400 | 19,400 | 19,400 | 19,400 | 97,000 |
| 4 | ប្រព័ន្ធស្រោចស្រពខ្នាតតូច | 4,600 | 4,600 | 4,600 | 4,600 | 4,600 | 23,000 |
| 5 | អនាម័យ និងបរិស្ថាន | 825 | 825 | 825 | 825 | 825 | 4,125 |
| 6 | មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ | 255 | 255 | 255 | 255 | 255 | 1,275 |
| 7 | សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ | 585 | 585 | 585 | 585 | 585 | 2,925 |
| 8 | អភិវឌ្ឍន៍ភូមិចម្រុះ | 514 | 514 | 514 | 514 | 514 | 2,570 |
| 9 | ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ | 270 | 270 | 270 | 270 | 270 | 1,350 |
| ១០ | ការបញ្ជ្រាបការយល់ដឹងស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ | 80 | 90 | 100 | 110 | 120 | 500 |
| 11 | ផ្តល់មុខជំនាញជាមូលដ្ឋានលើការផលិតចង្រ្កានជីវឧស្ម័ននិងចង្រ្កានកែលម្អ | 66 | 66 | 66 | 66 | 66 | 330 |
| 12 | ផ្តល់មុខជំនាញជាមូលដ្ឋាន និងបង្កើតការងារ | 100 | 100 | 100 | 100 | 100 | 500 |
| 13 | ការស្រាវជ្រាវនិងផ្តល់ព័ត៌មានទីផ្សារផលិតផល | 12 | 12 | 12 | 12 | 12 | 60 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 14 | ការអភិវឌ្ឍសហគ្រាសនិងជំនួញខ្នាតតូច | 630 | 630 | 630 | 630 | 630 | 3,150 |
| 15 | បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្រាវជ្រាវជនជាតិដើមភាគតិច | 972 | 972 | 30 | 30 | 30 | 2,034 |
| 16 | គាំទ្រដំណើរការសវនកម្ម | 53 | 53 | 53 | 53 | 53 | 265 |
| 17 | ការអប់រំផ្សព្វផ្សាយ និងស្រាវជ្រាវ | 128 | 128 | 128 | 128 | 128 | 640 |
| 18 | ការអភិវឌ្ឍធនធានមនុស្ស | 700 | 700 | 700 | 700 | 700 | 3,500 |
| 19 | មជ្ឈមណ្ឌលបណ្តុះបណ្តាល ជំនាញមូលដ្ឋាន | 300 | 300 | 310 | 310 | 310 | 1530 |
| 20 | ការអភិវឌ្ឍធនធានមនុស្ស(រដ្ឋបាល) | 20 | 20 | 20 | 20 | 20 | 100 |

## គម្រោងកំពុងដំណើរការ

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1 | គម្រោងផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ជំហាន ២ | | | | | | 25,800 |
| 2 | គម្រោងផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ជំហាន ៣ | | | | | | 20,000 |
| 3 | គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យ | | | | | | 8,488 |
| 4 | ផែនការសុវត្ថិភាពទឹក | | | | | | 340 |
| 5 | ឥណទានក្រសួងអភិវឌ្ឍន៍ជនបទ | | | | | | 660 |
| 6 | គម្រោងកេតសាណា | | | | | | 40,000 |
| 7 | កែលម្អផ្លូវពីកម្រាលក្រួសក្រហមទៅជាកម្រាលកៅស៊ូ | | | | | | 69,000 |
| 8 | ការអភិវឌ្ឍជនបទតាមវិធីសាស្រ្តចលនាភូមិថ្មី | | | | | | 8,000 |

## ១១-តារាងតាមដាន និងវាយតម្លៃការអនុវត្ត ផយអជ ២០១៤-២០១៨

| សូចនាករ/សកម្មភាព | ចំណុចចាប់ផ្តើម | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| 90% នៃថវិកាជាតិ និងថវិកាដៃគូ ត្រូវបានតាមដានលើការអនុវត្ត សកម្មភាពនៅតាមអនុកម្មវិធី ដោយប្រើទម្រង់ P និង M | លទ្ធផលក្នុង ឆ្នាំ ២០១៤ | ត្រីមាស | ត្រីមាស | ត្រីមាស | ត្រីមាស | ត្រីមាស |
| ការប្រមូលទិន្នន័យដោយទៀងទាត់ | | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ |

| | | | | | | |
|---|---|---|---|---|---|---|
| ការគ្រប់គ្រង និង ការវាយតម្លៃសូចនាករ ពីគុណភាពសម្រាប់អនុកម្មវិធី | លទ្ធផលក្នុងឆ្នាំ ២០១៤ | | | | | |
| សម្របសម្រួលជាមួយដៃគូ ភ្នាក់ងារផ្សេងៗ និងមន្ទីរអភិវឌ្ឍន៍ជនបទលើការអនុវត្តសូចនាករកម្មវិធី NSDP, PIP and BP | លទ្ធផលក្នុងឆ្នាំ ២០១៤ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ |
| ធ្វើការតាមដានអង្កេតមិនប្រាប់ជាមុន ២៤ រាជធានី ខេត្ត ។ ធ្វើរបាយការណ៍ សូចនាករលទ្ធផលរបស់ក្រសួង។ | លទ្ធផលឆ្នាំ ២០១៤ | ប្រចាំឆ្នាំ | | ប្រចាំឆ្នាំ | | ប្រចាំឆ្នាំ |
| | លទ្ធផលឆ្នាំ ២០១៤ | ប្រចាំឆមាស | ប្រចាំឆមាស | ប្រចាំឆមាស | ប្រចាំឆមាស | ប្រចាំឆមាស |
| ការប្រើប្រាស់ទិន្នន័យសិក្ខាសាលា និងរបាយការណ៍សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ | លទ្ធផលឆ្នាំ ២០១៤ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| យ៉ាងតិច ៩០% នៃមន្ត្រីតាមដាន និងវាយតម្លៃ និងផែនការ បានចូលរួមអនុវត្តតាមជំនាញក្នុងការអភិវឌ្ឍតាមកម្មវិធីដើម្បីភ្ជាប់រវាង ផែនការថវិកា និងការតាមដាន និងវាយតម្លៃ ។ | លទ្ធផលពីឆ្នាំ ២០១៤ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ទាក់ទងនឹងសកម្មភាពផ្សេងៗ សម្រាប់ភារកិច្ចតាមដាន និងវាយតម្លៃ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ | ប្រចាំខែ |

## ១២-តារាងតាមដានសូចនាករការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៤-២០១៨

| Indicator | Unit | 2012 ជាក់ស្តែង | 2013 ព្យាករណ៍ | 2014 ប៉ាន់ស្មាន | 2015 ប៉ាន់ស្មាន | 2016 ប៉ាន់ស្មាន | 2017 ប៉ាន់ស្មាន | 2018 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|
| ការស្តារ និងសាងសង់ផ្លូវជនបទ ( លើប្រវែងសរុប ៤០០០០ គម) | គម | 26,900 | 27,750 | 28,600 | 29,450 | 30,300 | 31,150 | 32,000 |
| ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ ( DBST ) ឬបេតុង | គម | - | 125 | 550 | 980 | 1,430 | 1,880 | 2,330 |
| ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | 42.00 | 44.20 | 46.70 | 50.00 | 53.00 | 56.00 | 60.00 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | 33.30 | 37.50 | 42.00 | 46.00 | 50.00 | 55.00 | 60.00 |
| ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | សហគមន៍ | 80 | 100 | 130 | 160 | 190 | 220 | 250 |
| ចំនួនភូមិដែលបានបណ្តុះបណ្តាល គអភ ស្តីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | 673 | 1610 | 1800 | 2000 | 2200 | 2400 | 2600 |
| សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ ៤៥០ គមដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ១០០% | គម | 0 | 0 | 67.50 | 90.00 | 112.50 | 137.50 | 162.50 |
| កសាងសមត្ថភាពគ.អ.ភ ស្តីពីជំរើសនៃបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គអភ | 0 | 0 | 1854 | 2472 | 3091 | 2472 | 2472 |

## ១៣-សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលដូចបានបង្ហាញខាងលើ យើងអាចសន្និដ្ឋានបានថា ឆ្លងកាត់ការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ២ តាមរយៈផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ - ២០១៣ ក្រសួងអភិវឌ្ឍន៍ជនបទ បានបំពេញកិច្ចការយ៉ាងច្រើនតាមដំណាក់កាលនីមួយៗនៃផែនការដែលបានគ្រោងទុកធ្វើឲ្យតំបន់ជនបទប្រែមុខមាត់ថ្មីតាមរយៈសមិទ្ធផលយ៉ាងច្រើនរួមមានផ្លូវជនបទចាប់ផ្តើមក្រាលកៅស៊ូ និងបេតុងជាបណ្តើរៗហើយ ស្ពាន លូទឹក សំណង់សិល្បការនានា ប្រព័ន្ធធារាសាស្រ្ត អណ្តូងទឹកស្អាត បង្គន់អនាម័យដែលក្រសួងអភិវឌ្ឍន៍ជនបទបានកសាងឡើងជូនដល់ប្រជាពលរដ្ឋនៅតាមជនបទ ។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធជនបទ ក្រសួងក៏បានខិតខំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានជូនប្រជាពលរដ្ឋ បង្កើតមុខរបរជូនប្រជាពលរដ្ឋ និងផ្តល់ឥណទានដល់ប្រជាពលរដ្ឋក្នុងអត្រាការប្រាក់ទាបដើម្បីឲ្យប្រជាពលរដ្ឋមានលទ្ធភាពបង្កើតមុខរបរអាជីវកម្មរបស់គាត់ដើម្បីបង្កើនប្រាក់ចំណូលប្រចាំគ្រួសារឈានទៅកាត់បន្ថយភាពក្រីរបស់ប្រជាពលរដ្ឋ ។

ក្រសួងអភិវឌ្ឍន៍ជនបទសង្ឃឹមថារយៈពេល ៥ ឆ្នាំខាងមុខនេះ តំបន់ជនបទនឹងមានការប្រែប្រួលកាន់តែខ្លាំងជាងនេះ ហើយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទនឹងកាន់តែមានភាពល្អប្រសើរឡើង ធ្វើឲ្យគម្លាតរវាងទីក្រុង និងតំបន់ជនបទត្រូវបានកាត់បន្ថយ ។




(Source: www.mef.gov.kh)

# រចនាសម្ព័ន្ធក្រសួងអភិវឌ្ឍន៍ជនបទ

